# លទ្ធផលនៃការអង្កេតថ្នាក់ជាតិស្តីពីអភិបាលកិច្ចមូលដ្ឋានរបស់ផ.អ.៣ ឆ្នាំ២០១៦

## លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ឯកសារនេះបង្ហាញពីការវាយតម្លៃនិន្នាការអភិបាលកិច្ចមូលដ្ឋាននៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដោយផ្អែកលើការសម្ភាសជាមួយប្រជាពលរដ្ឋជាតំណាងគ្រួសារប្រមាណជា១.៣៨៤នាក់ ក្រុមប្រឹក្សាចំនួន៧១៩រូប និងគណៈអភិបាលចំនួន៥០រូប។ ការអង្កេតនេះបានធ្វើឡើងកាលពីឆ្នាំ២០១១ ឆ្នាំ២០១៣ និងឆ្នាំ២០១៦ ដោយពិនិត្យមើលលើការចូលរួមរបស់ប្រជាពលរដ្ឋ តម្លាភាព គណនេយ្យភាព ការបន្ស៊ីផ្អែកគោលនយោបាយ ការឆ្លើយតប ការលើកកម្ពស់និងការការពារក្រុមជនងាយរងគ្រោះ អន្តររដ្ឋបាល និងការផ្តល់សេវា។ លទ្ធផលនៃការអង្កេតបង្ហាញថាសន្ទស្សន៍នៃអភិបាលកិច្ចមូលដ្ឋានមានការកើនឡើងគួរឲ្យកត់សម្គាល់ក្នុងអត្ថន័យស្ថិតិពីឆ្នាំ២០១៣-១៦។

# មាតិកា


សេចក្តីសង្ខេបរួម ..... iv

សេចក្តីផ្តើម និងវិធីសាស្ត្រនៃការអង្កេត ..... iv

និន្នាការរួម ..... v

ការផ្តល់សេវា ..... vi

ការបន្សុីផ្នែកគោលនយោបាយ ..... vi

ការឆ្លើយតប ..... vi

ការការពារ និងគាំទ្រក្រុមជនងាយរងគ្រោះ ..... vii

ការចូលរួមរបស់ប្រជាពលរដ្ឋ ..... vii

តម្លាភាព ..... viii

គណនេយ្យភាព ..... viii

អន្តររដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ..... ix

ការបកស្រាយ និងឱកាសសម្រាប់អនុវត្ត ..... ix

1. សេចក្តីផ្តើម ..... 1

1.1 សាវតា ..... 1

1.1.1 អភិបាលកិច្ចមូលដ្ឋាន ..... 1

1.2 វិធីសាស្ត្រ ..... 1

1.2.1 ដែនកំណត់នៃការអង្កេត ..... 2

1.2.2 សន្ទស្សន៍ ..... 3

1.2.3 មាត្រដ្ឋានតាង ..... 4

1.3 សេចក្តីសន្និដ្ឋាន ..... 4

1.4 ការអង្កេតផ្សេងទៀត និងនិន្នាការនៃអភិបាលកិច្ច ..... 4

2. ការផ្តល់សេវា ..... 6

2.1 និន្នាការនៃការផ្តល់សេវា ..... 6

2.2 តើសេវាណាមួយដែលប្រជាពលរដ្ឋពេញចិត្តជាងគេក្នុងឆ្នាំ២០១៦? ..... 6

3. ការបន្សុីផ្នែកគោលនយោបាយ ..... 8

3.1 និន្នាការនៃការបន្សុីផ្នែកគោលនយោបាយ ..... 8

3.2 តើប្រជាពលរដ្ឋនិយាយអ្វីខ្លះ? ..... 8

3.3 ទំនាក់ទំនងស្ថិតិ ....8
4. ការឆ្លើយតប ....11
4.1 និន្នាការនៃការឆ្លើយតបរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ....11
4.2 តើប្រជាពលរដ្ឋបានដឹងអំពីយន្តការដោះស្រាយបណ្តឹងដែរ ឬទេ? ....11
4.3 តើប្រជាពលរដ្ឋមានការពេញចិត្តជាមួយនឹងការដោះស្រាយបណ្តឹងដែរ ឬទេ? ....12
4.4 ការវាយតម្លៃជារួមអំពីការឆ្លើយតប ....12
4.5 តើប្រជាពលរដ្ឋដាក់ពាក្យបណ្តឹងដែរ ឬទេ ពេលដែលគាត់ចង់ប្តឹង? ....12
5. ការការពារ និងគាំទ្រក្រុមជនងាយរងគ្រោះ ....14
5.1 និន្នាការនៃការការពារ និងគាំទ្រក្រុមជនងាយរងគ្រោះ ....14
5.2 ការប្រៀបធៀបតាមក្រុម ....14
6. ការចូលរួមរបស់ប្រជាពលរដ្ឋ ....16
6.1 និន្នាការនៃសន្ទស្សន៍ការចូលរួមរបស់ប្រជាពលរដ្ឋ ....16
6.2 ទំនាក់ទំនងក្រៅផ្លូវការ ....16
6.3 ទំនាក់ទំនងផ្លូវការ និងកិច្ចប្រជុំ ....17
6.4 សង្គមស៊ីវិល ....18
7. តម្លាភាព និងការរាយការណ៍ ....25
7.1 និន្នាការនៃតម្លាភាព ....25
7.2 តម្រូវការព័ត៌មាន ....25
7.3 ការផ្តល់ព័ត៌មានដែលស្នើសុំ ....26
7.4 ការពេញចិត្តនឹងការផ្តល់ព័ត៌មាន ....26
7.5 ការទទួលបានព័ត៌មានពីតម្លៃ ....26
8. គណនេយ្យភាព និងអំពើពុករលួយ ....30
8.1 និន្នាការនៃគណនេយ្យភាព ....30
8.2 តើមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិមានគណនេយ្យភាពលើអ្វីខ្លះ? ....30
8.3 អំពើពុករលួយ ....31
9. អន្តររដ្ឋបាល ....33
10. និន្នាការ ....33
11. ការមិនយល់ស្របគ្នា និងដំណោះស្រាយ ....34
12. ការគាំទ្រដោយថ្នាក់រដ្ឋបាលផ្សេងទៀត ....34
13. ការអន្តរាគមន៍ សេរីភាព និងស្វ័យភាព ....34

14. ព័ត៌មាន និងការឆ្លើយតប ....35
15. ទំនាក់ទំនងនៃសិទ្ធិអំណាចរវាងក្រុមប្រឹក្សា និងគណៈអភិបាល ....35
10. សមាគមក្រុមប្រឹក្សា ....38
10.1 សេចក្តីផ្តើម ....38
10.2 លទ្ធផលនៃការវាយតម្លៃ ....38
ឧបសម្ព័ន្ធ៖ ឯកសារយោង ....40

# សេចក្តីសង្ខេបរួម

## សេចក្តីផ្តើម និងវិធីសាស្រ្តនៃការអង្កេត

របាយការណ៍នេះបង្ហាញពីការអង្កេតនិងវាយតម្លៃអំពីស្ថានភាពនៃអភិបាលកិច្ចមូលដ្ឋាន ដោយផ្អែកលើទស្សនៈរបស់ប្រជាពលរដ្ឋ និងការប្រៀបធៀបលទ្ធផលនៃការអង្កេតបន្តឆ្នាំ២០១៦ ជាមួយលទ្ធផលនៃការអង្កេតបន្តឆ្នាំ២០១៣ និងលទ្ធផលនៃការអង្កេតដើមគ្រាឆ្នាំ២០១១។ ដូចនេះ ការអង្កេតនេះធ្វើឡើង ដើម្បីតាមដាននិងពិនិត្យពីការប្រែប្រួលនៃអភិបាលកិច្ចមូលដ្ឋាន។ ការអង្កេតនីមួយៗមានសំណួរប្រមាណជា២៥០ ហើយទិន្នន័យនៃការអង្កេតទាំងអស់បានប្រមូលដោយក្រុមហ៊ុនស្រាវជ្រាវឯករាជ្យ និងវិភាគដោយលេខាធិការដ្ឋានគ.ជ.អ.ប។ ការអង្កេតសម្រាប់ឆ្នាំ២០១៦បានធ្វើឡើងតាមរយៈការសម្ភាសជាមួយអ្នកផ្តល់សម្ភាស២.១១៣រូប រួមមាន ប្រជាពលរដ្ឋជាតំណាងគ្រួសារ ចំនួន១.៣៨៤រូប ក្រុមប្រឹក្សាចំនួន៧១៩រូប និង គណៈអភិបាលចំនួន៥០រូប នៅក្នុងភូមិចំនួន១៩២ ឃុំ សង្កាត់ចំនួន៩៦ និងក្រុង ស្រុក ខណ្ឌចំនួន៤៨ នៃរាជធានី ខេត្តចំនួន១៣។

អភិបាលកិច្ចត្រូវបានឲ្យនិយមន័យថា "ជារបៀបដែលសិទ្ធិ ឬអំណាចត្រូវបានប្រើប្រាស់" ឬជារបៀបដែលសង្គមបានរៀបចំខ្លួន ដើម្បីកំណត់និងអនុវត្តនូវសេចក្តីសម្រេចចិត្តរួម។ ការអង្កេតនេះធ្វើឡើង ដើម្បីពិនិត្យនិងវាយតម្លៃនូវស្ថានភាពរបស់ចំណុចសំខាន់ៗចំនួន៩ រួមមានការចូលរួមរបស់ប្រជាពលរដ្ឋ តម្លាភាព គណនេយ្យភាព ការបន្សុីផ្នែកគោលនយោបាយ ការឆ្លើយតប ការលើកកម្ពស់និងការពារសិទ្ធិក្រុមជនងាយរងគ្រោះ អន្តររដ្ឋបាល និងការផ្តល់សេវា។ ចំណុចនីមួយៗ មានអថេរជាច្រើន ដែលត្រូវបានដាក់បញ្ចូលគ្នា ដើម្បីបង្កើតជាសន្ទស្សន៍ពី០ដល់១០០។ ទិន្នន័យអង្កេតនេះបានប្រើប្រាស់សម្រាប់ធ្វើសេចក្តីសន្និ-ដ្ឋានថា តើសន្ទស្សន៍មានការកើនឡើងឬថយចុះ និងមានការប្រែប្រួលគួរឲ្យកត់សម្គាល់យ៉ាងណា ជាមួយនឹងកម្រិតនៃការជឿទុកចិត្ត៩៥%។

ការអង្កេតទាំង៣លើកនេះមានដែនកំណត់មួយចំនួន ហើយលទ្ធផលនៃការអង្កេតនេះ

**រូបភាពទី១: ក្របខណ្ឌអភិបាលកិច្ចមូលដ្ឋាន និងសន្ទស្សន៍**




**រូបភាពទី២: សន្ទស្សន៍រួមនៃអភិបាលកិច្ចមូលដ្ឋាន (មាត្រដ្ឋានពី០-១០០)**




**តារាងទី១: សន្ទស្សន៍អង្គការសង្គមស៊ីវិលមូលដ្ឋាន និងសន្ទស្សន៍រដ្ឋបាលថ្នាក់ក្រោមជាតិ (បម្រែបម្រួលជា%)**

| សន្ទស្សន៍ | 2011-13 | 2013-16 | 2011-16 |
|---|---|---|---|
| រដ្ឋបាលថ្នាក់ក្រោមជាតិ | -9.16 | 6.14 | -3.58 |
| អង្គការសង្គមស៊ីវិលនៅមូលដ្ឋាន | -7.35 | -4.56 | -11.57 |

គួរធ្វើការបកស្រាយដោយមានការប្រុងប្រយ័ត្ន។ ការអង្កេតបានស្ទាបស្ទង់នូវទស្សនៈ និងកត់ត្រានូវអ្វីដែលប្រជាពលរដ្ឋនិយាយជាជាងអ្វីដែលពួកគាត់បានធ្វើ។ ម្យ៉ាងទៀត ការអង្កេតនេះក៏ដូចជាការអង្កេតផ្សេងទៀតដែលបានធ្វើឡើងដោយស្ថាប័នផ្សេងទៀតក្នុងប្រទេសកម្ពុជាបង្ហាញថាលទ្ធផលនៃការអង្កេតឆ្នាំ២០១៣ គឺខុសពីលទ្ធផលនៃការអង្កេតឆ្នាំ២០១១។ បន្ទាប់ពីមានការបោះឆ្នោតជាតិ ប្រជាពលរដ្ឋចាប់ផ្តើមមានឆន្ទៈក្នុងការបញ្ចេញមតិយោបល់ដោយបើកចំហ និងការរំពឹងទុករបស់ពួកគាត់ក៏មានការផ្លាស់ប្តូរផងដែរ។ ទន្ទឹមនេះ ការប្រមូលទិន្នន័យសម្រាប់ការអង្កេតដើមគ្រា និងការអង្កេតបន្តត្រូវបានធ្វើឡើងដោយក្រុមហ៊ុន២ផ្សេងគ្នា ហើយកូដទិន្នន័យនៃការអង្កេតដើមគ្រាមួយចំនួនមានភាពមិនស៊ីគ្នាជាមួយនឹងទិន្នន័យនៃការអង្កេតបន្តទាំង២លើកដែលហេតុនាំឲ្យប៉ះពាល់ដល់គុណភាពទិន្នន័យ។

## និន្នាការរួម

ដូចដែលមានបង្ហាញនៅក្នុង**រូបភាពទី២** សន្ទស្សន៍អភិបាលកិច្ចមូលដ្ឋានមានការធ្លាក់ចុះគួរឲ្យកត់សម្គាល់ក្នុងអត្ថន័យស្ថិតិពីឆ្នាំ២០១១-១៣ ប៉ុន្តែសន្ទស្សន៍នេះមានការកើនឡើងគួរឲ្យកត់សម្គាល់ក្នុងអត្ថន័យស្ថិ-តិពីឆ្នាំ២០១៣-១៦។

ការអង្កេតនេះបានប្រើសំណួរជាច្រើនដែលស្ទាបស្ទង់ទស្សនៈរបស់ប្រជាពលរដ្ឋអំពីប្រសិទ្ធភាពអភិបាលកិច្ចនៃអង្គការសង្គមស៊ីវិលក្នុងមូលដ្ឋាន ដើម្បីប្រៀបធៀបនឹងអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ដូចបានបង្ហាញក្នុង**តារាងទី១** ទោះបីជាការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិធ្លាក់ចុះជាងការអនុវត្តការងាររបស់អង្គការសង្គមស៊ីនៅមូលដ្ឋានពីឆ្នាំ២០១១-១៣ក៏ដោយ ក៏រដ្ឋបាលថ្នាក់ក្រោមជាតិបានអនុវត្តការងាររបស់ខ្លួនបានល្អប្រសើរជាងអង្គការសង្គមស៊ីវិលនៅមូលដ្ឋានពីឆ្នាំ២០១១-១៦ និងពីឆ្នាំ២០១៣-១៦ដែរ។ ប្រជាពលរដ្ឋយល់ថាការអនុវត្តការងាររបស់អង្គការសង្គមស៊ីវិលនៅមូលដ្ឋានមានការថយចុះ ហើយការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានជំរុញឲ្យកាន់តែប្រសើរឡើង តាមរយៈកត្តាខាងក្រៅមួយចំនួន រួមមានស្ថេរភាពនយោបាយជាដើម។

**រូបភាពទី៣: សន្ទស្សន៍មានការកើនឡើង**




**រូបភាពទី៤: សន្ទស្សន៍មានការធ្លាក់ចុះ**




**រូបភាពទី៥: សន្ទស្សន៍រួមទាំង៨**



ជារួម សន្ទស្សន៍ចំនួន៥បានធ្លាក់ចុះពីឆ្នាំ២០១១-១៣ ហើយសន្ទស្សន៍ទាំងនេះបានកើនឡើងវិញពីឆ្នាំ២០១៣-១៦ **រូបភាពទី៣**។ ទន្ទឹមនេះ សន្ទស្សន៍ចំនួន៣មានការធ្លាក់ចុះជាបន្តបន្ទាប់ពីឆ្នាំ២០១១-១៦ **រូបភាពទី៤**[1]។

ទិន្នន័យទាំងនេះអាចបកស្រាយបានច្រើនរបៀប រួមមាន៖ (១). ទិន្នន័យអាចឆ្លុះបញ្ចាំងពីនិន្នាការនៃអភិបាលកិច្ចមូលដ្ឋាន និងការអនុវត្តការងារជាក់ស្តែងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២). ទិន្នន័យអង្កេតដើមគ្រាឆ្នាំ២០១១មានភាពមិនប្រក្រតីខ្លះ ដោយសារគុណភាពនៃទិន្នន័យនៅមានកម្រិតដែលជាហេតុធ្វើឲ្យលទ្ធផលនៃការអង្កេតខ្ពស់ (៣). ការបោះឆ្នោត ការផ្លាស់ប្តូរផ្នែកសេដ្ឋកិច្ច ឬការផ្លាស់ប្តូរផ្សេងៗទៀតនៅទូទាំងប្រទេស និងកត្តាខាងក្រៅមួយចំនួនទៀតដែលកើតឡើងតាំងពីឆ្នាំ២០១៣ បានធ្វើឲ្យមានការផ្លាស់ប្តូរការរំពឹងទុករបស់ប្រជាពលរដ្ឋមូលដ្ឋាន។ កត្តាទាំងនេះធ្វើឲ្យមានភាពលំបាកក្នុងការធ្វើសេចក្តីសន្និដ្ឋានរួមអំពីស្ថានភាពអភិបាលកិច្ចមូលដ្ឋាន។

## ការផ្តល់សេវា

អំឡុងឆ្នាំ២០១៦ ប្រជាពលរដ្ឋមានការពេញចិត្តទៅនឹងការផ្តល់សេវាជាងឆ្នាំ២០១១ (+៣%) និងឆ្នាំ២០១៣ (+១៤%)។ និន្នាការនៃការពេញចិត្តនឹងការផ្តល់សេវាមានការកើនឡើងពីឆ្នាំ២០១១-១៦ និងពីឆ្នាំ២០១៣-១៦ ដែលជាការកើនឡើងមួយគួរឲ្យកត់សម្គាល់ក្នុងអត្ថន័យស្ថិតិ **រូបភាពទី៣**។ ការផ្តល់សេវាមានភាពប្រសើរឡើងទាំងនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ **រូបភាពទី៦**។

**រូបភាពទី៦: ការពេញចិត្តនឹងការផ្តល់សេវាមានការកើនឡើងពីឆ្នាំ២០១៣-១៦**




## ការបន្សុីផ្នែកគោលនយោបាយ

ការបន្សុីផ្នែកគោលនយោបាយបង្ហាញពីកម្រិតនៃតម្រូវការអាទិភាព និងសកម្មភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលឆ្លុះបញ្ចាំងពីតម្រូវការប្រជាពលរដ្ឋរស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ សន្ទស្សន៍នេះមានការធ្លាក់ចុះពីឆ្នាំ២០១១-១៣ និងពីឆ្នាំ២០១៣-១៦ **រូបភាពទី៤**។

## ការឆ្លើយតប

ការឆ្លើយតបបង្ហាញនូវកម្រិតដែលរដ្ឋបាលថ្នាក់ក្រោមជាតិធ្វើការឆ្លើយតបទៅនឹងបញ្ហាផ្សេងៗដែលប៉ះពាល់ដល់ប្រជាពលរដ្ឋមូលដ្ឋាន។ ការអង្កេតអភិបាលកិច្ចមូលដ្ឋានបានផ្តោតលើការដោះស្រាយបណ្តឹង និងទស្សនៈទូទៅរបស់ប្រជាពលរដ្ឋមូលដ្ឋាន។ លទ្ធផលនៃការអង្កេតបង្ហាញថា៖

- ⇩ អំឡុងឆ្នាំ២០១៦ ប្រមាណជា៨៤% នៃប្រជាពលរដ្ឋមូលដ្ឋានអាចកំណត់យន្តការដោះស្រាយបណ្តឹងនៅរដ្ឋបាលឃុំ សង្កាត់បានយ៉ាងហោចណាស់ចំនួន១ ដែលតួលេខនេះមានធ្លាក់ចុះពីឆ្នាំ២០១៣ (៩០%)។
- ⇧ អំឡុងឆ្នាំ២០១៦ ប្រមាណជា១២% នៃប្រជាពលរដ្ឋទាំងអស់អាចកំណត់យន្តការដោះស្រាយបណ្តឹងនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលតួលេខនេះមានការកើនឡើងពីតួលេខកាលពីឆ្នាំ២០១១ (៦%) និងឆ្នាំ២០១៣ (៩%)។ ទោះបីជាយ៉ាងនេះក្តី តួលេខនេះគឺនៅមានកម្រិតទាបនៅឡើយ។

[1] ដូចបានរៀបរាប់ពីខាងដើម ការផ្លាស់ប្តូរនេះអាចបណ្តាលមកពីកត្តាស្ថានភាពនយោបាយ ជាជាងការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- ⇩ ប្រជាពលរដ្ឋត្រូវបានសាកសួរថា "តើគាត់ធ្លាប់មានហេតុផលណាមួយដែលធ្វើឲ្យគាត់ចង់ដាក់ពាក្យបណ្ដឹង និងដាក់ពាក្យបណ្ដឹងដែរ ឬទេ?"។ អំឡុងឆ្នាំ២០១៦ ប្រមាណជា៧០% នៃប្រជាពលរដ្ឋធ្លាប់ចង់ដាក់ពាក្យបណ្ដឹង ប៉ុន្តែមិនបានដាក់ពាក្យបណ្ដឹង ដែលតួលេខនេះច្រើនជាង២ដងនៃតួលេខកាលពីឆ្នាំ២០១១។ លទ្ធផលនេះអាចនឹងឆ្លុះបញ្ចាំងពីការលំបាកក្នុងការស្វែងរក និងទទួលបានយន្តការដោះស្រាយបណ្ដឹង ព្រមទាំងការយល់ឃើញថាបណ្ដឹងរបស់ប្រជាពលរដ្ឋនឹងមិនអាចទទួលបាននូវការដោះស្រាយសមស្របណាមួយ។
- ⇧ ទោះបីមានប្រជាពលរដ្ឋមួយចំនួនតូចបានលើកឡើងថាគាត់ធ្លាប់បានដាក់ពាក្យបណ្ដឹង ប៉ុន្តែពួកគាត់មានការពេញចិត្តនឹងដំណោះស្រាយ។
- ⇧ ជារួម ប្រជាពលរដ្ឋមូលដ្ឋានយល់ថារដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ កាន់តែមានការឆ្លើយតប។

## ការការពារ និងគាំទ្រក្រុមជនងាយរងគ្រោះ

គោលបំណងរបស់ផ.អ.៣ ជួយរដ្ឋបាលថ្នាក់ក្រោមជាតិបំពេញភារកិច្ចរបស់ខ្លួនឲ្យបានកាន់តែប្រសើរដើម្បីលើកកម្ពស់សម្លេង សិទ្ធិ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមូលដ្ឋាន ពិសេសក្រុមជនងាយរងគ្រោះ។ ប្រជាពលរដ្ឋត្រូវបានសាកសួរដើម្បីវាយតម្លៃពីកម្រិតដែលក្រុមផ្សេងៗគ្នាទទួលបានការពារ និងគាំទ្រដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ យោងតាមសន្ទស្សន៍អភិបាលកិច្ចមូលដ្ឋាន ការជួយការពារ និងគាំទ្រក្រុមជនងាយរងគ្រោះមានការកើនឡើងពីឆ្នាំ២០១៣-១៦ និងពីឆ្នាំ២០១១-១៦។ ការផ្លាស់ប្ដូរទាំងនេះមានការកើនឡើងគួរឲ្យកត់សម្គាល់ក្នុងអត្ថន័យស្ថិតិ **រូបភាពទី៣**។

ដូចគ្នាទៅនឹងលទ្ធផលនៃការអង្កេតលើកមុនដែរ ការការពារស្ត្រីនិងកុមារមានលក្ខណៈប្រសើរជាងការការពារក្រុមផ្សេងទៀត ដូចជាក្រុមជនជាតិដើមភាគតិច។ ការសម្រេចបានទាំងនេះអាចជាលទ្ធផលនៃការអភិវឌ្ឍសមត្ថភាពគណៈកម្មាធិការស្ត្រីនិងកុមារ និងការបញ្ជ្រាបយេនឌ័រក្នុងក្របខ័ណ្ឌ ផ.អ.៣។

ការគាំទ្រក្រុមទាំងអស់ (លើកលែងតែក្រុមស្ត្រី និងកុមារ) មានភាពប្រសើរឡើងពីឆ្នាំ២០១៣-១៦ និងពីឆ្នាំ២០១១-១៦ **រូបភាពទី៧**។

**រូបភាពទី៧: ការការពារនិងគាំទ្រដល់ក្រុមជនងាយរងគ្រោះ (ការវាយតម្លៃជាមធ្យម)**




ចំណាំ: 0=មិនល្អ ២៥=មិនសូវល្អ ៥0=មធ្យម ៧៥=ល្អ ១00=ល្អណាស់

## ការចូលរួមរបស់ប្រជាពលរដ្ឋ

ផ្នែកនេះរៀបរាប់ពីរបៀបដែលប្រជាពលរដ្ឋធ្វើការម្នាក់ៗ ឬជាក្រុម តាមរយៈអង្គការសង្គមស៊ីវិល ដើម្បីជំរុញការសម្រេចចិត្តសាធារណៈឲ្យកាន់តែមានភាពប្រសើរឡើង។ សន្ទស្សន៍ការចូលរួមរបស់ប្រជាពលរដ្ឋមានការធ្លាក់ចុះជាបន្តបន្ទាប់ពីឆ្នាំ២០១១។ លទ្ធផលនៃការអង្កេតអភិបាលកិច្ចមូលដ្ឋានបង្ហាញថា៖

- ⇧ ទំនាក់ទំនងក្រៅផ្លូវការរវាងប្រជាពលរដ្ឋនិងក្រុមប្រឹក្សា ពិសេសនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ មានការកើនឡើង។ ប្រមាណជា២០%នៃប្រជាពលរដ្ឋទាំងអស់ធ្លាប់ទទួលបានការទំនាក់ទំនងពីក្រុមប្រឹក្សាឃុំ សង្កាត់ ខណៈដែលមានតែប្រមាណជា៨%នៃប្រជាពលរដ្ឋទាំងអស់ធ្លាប់ទទួលបានការទំនាក់ទំនងពីក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ។ ជារួម ក្រុមប្រឹក្សាធ្លាប់ធ្វើការទំនាក់ទំនងទៅប្រជាពលរដ្ឋជាជាងប្រជាពលរដ្ឋទំនាក់ទំនងទៅក្រុមប្រឹក្សាវិញ។
- ⇧ អំឡុងឆ្នាំ២០១៦ ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចប្រជុំក្រៅផ្លូវការនៅរដ្ឋបាលថ្នាក់ក្រោមជាតិមានកម្រិតខ្ពស់ជាងឆ្នាំ២០១៣ និងឆ្នាំ២០១១ ពិសេសនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ លទ្ធផលនៃការអង្កេតបង្ហាញថា ប្រមាណជា២៩%នៃប្រជាពលរដ្ឋទាំងអស់ធ្លាប់បានចូលរួមកិច្ចប្រជុំទាំងនេះ។
- ⇩ ប្រជាពលរដ្ឋយល់ឃើញថាកិច្ចប្រជុំដែលរៀបចំឡើងដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ក្នុងអំឡុងឆ្នាំ២០១៦ មិនសូវមានសារៈសំខាន់ បើធៀបទៅនឹងឆ្នាំ២០១១ និងឆ្នាំ២០១៣។ ការយល់ឃើញដូចនេះ ព្រោះប្រជាពលរដ្ឋយល់ថាភាពងាយស្រួលក្នុងការចូលរួមកិច្ចប្រជុំ សារៈសំខាន់នៃបញ្ហាដែលលើកយកមកពិភាក្សាក្នុងកិច្ចប្រជុំ គុណភាពនៃការធ្វើសេចក្តីសម្រេចចិត្ត និងការទទួលយកនូវមតិយោបល់ផ្សេងៗក្នុងកិច្ចប្រជុំ មានការធ្លាក់ចុះ។
- ⇩ អំឡុងឆ្នាំ២០១៦នេះ ចំនួនប្រជាពលរដ្ឋដែលធ្លាប់បានបញ្ចេញមតិយោបល់ក្នុងកិច្ចប្រជុំមានកាន់តែតិចបើធៀបទៅនឹងឆ្នាំ២០១១-១៣។
- ⇩ ប្រជាពលរដ្ឋយល់ថាអង្គការសង្គមស៊ីវិលនៅមូលដ្ឋានសហការនិងចូលរួមជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ មិនសូវមានប្រសិទ្ធិភាព។ ទន្ទឹមនេះ ភាពជាតំណាងរបស់អង្គការសង្គមស៊ីវិលនៅមូលដ្ឋាន និងការបំពេញការងារ ដើម្បីលើកកម្ពស់និងការពារក្រុមជនងាយរងគ្រោះ មានការធ្លាក់ចុះ។

## តម្លាភាព

យោងតាមលទ្ធផលនៃការអង្កេតអភិបាលកិច្ចមូលដ្ឋាន សន្ទស្សន៍តម្លាភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានការកើនឡើងប្រមាណជា៥៤% ពីឆ្នាំ២០១១-១៦ និងប្រមាណជា៣៧% ពីឆ្នាំ២០១៣-១៦ ដែលជាការកើនឡើងគួរឲ្យកត់សម្គាល់មួយក្នុងអត្ថន័យស្ថិតិ។ ភាគច្រើននៃការផ្លាស់ប្តូរនេះអាចបណ្តាលមកពីវឌ្ឍនភាពរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។ ទោះបីមានចំនួនប្រជាពលរដ្ឋតិចជាងមុនដែលបានស្វែងរកព័ត៌មាន តែពួកគាត់មាន ឱកាសទទួលបានព័ត៌មានតាមតម្រូវការកាន់តែច្រើនជាងមុន។ អំឡុងឆ្នាំ២០១៦ ប្រមាណជា៦៦%នៃសំណើរបស់ប្រជាពលរដ្ឋទៅរដ្ឋបាលឃុំ សង្កាត់ និងប្រមាណជា៤៨%នៃសំណើរបស់ប្រជាពលរដ្ឋទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបានដោះស្រាយ។ ម្យ៉ាងទៀត ប្រជាពលរដ្ឋមានការពេញចិត្តនឹងព័ត៌មានដែលបានផ្តល់ជូន។ ចំនួនប្រជាពលរដ្ឋដែលគាត់គិតថាគាត់បានទទួលព័ត៌មានត្រឹមត្រូវអំពីតម្លៃសេវានៅរដ្ឋបាលថ្នាក់ក្រោមជាតិមានការកើនឡើង ដែលក្នុងនោះប្រមាណជា៨៦%នៃប្រជាពលរដ្ឋគិតថាគាត់បានទទួលព័ត៌មានត្រឹមត្រូវអំពីតម្លៃសេវានៅរដ្ឋបាលឃុំ សង្កាត់ និងប្រមាណជា៩៩%នៃប្រជាពលរដ្ឋគិតថាគាត់បានទទួលព័ត៌មានត្រឹមត្រូវអំពីតម្លៃសេវានៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

## គណនេយ្យភាព

នៅក្នុងដំណើរការអង្កេតអភិបាលកិច្ចមូលដ្ឋាននេះ គណនេយ្យភាពត្រូវបានឲ្យនិយមន័យថា "កាតព្វកិច្ចរបស់អាជ្ញាធរក្នុងការឆ្លើយនឹងសំណួរពាក់ព័ន្ធនឹងសកម្មភាពដែលបានធ្វើ ឬការប្រឈមនឹងការទទួលពិន័យនានាចំពោះទង្វើខុសឆ្គងរបស់ខ្លួន"។ និយមន័យនេះបង្ហាញពីភាពខុសគ្នារបស់អត្ថន័យនៃពាក្យគណនេយ្យភាព និងពាក្យការ

ឆ្លើយតប ទោះបីជាអត្ថន័យនៃពាក្យទាំងពីរនេះមានទំនាក់ទំនងគ្នាក៏ដោយ។ ពីឆ្នាំ២០១១-១៣ និងនៅឆ្នាំ២០១៦ សន្ទស្សន៍គណនេយ្យភាពមានការធ្លាក់ចុះ។ ហើយសន្ទស្សន៍នេះមានការធ្លាក់ចុះគួរឲ្យកត់សម្គាល់ក្នុងអត្ថន័យស្ថិតិពីឆ្នាំ២០១១ដល់២០១៦។

ប្រជាពលរដ្ឋជឿជាក់ថាមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិមានគណនេយ្យភាពតិចតួចចំពោះការអវត្តមានពីការងារ ឬការបំពេញការងារមិនបានល្អ ជាងគណនេយ្យភាពលើការគ្រប់គ្រងហិរញ្ញវត្ថុ។ លទ្ធផលនៃការអង្កេតអភិបាលកិច្ចមូលដ្ឋានឆ្នាំ២០១៣ និងឆ្នាំ២០១៦ គឺស្ទើរតែដូចគ្នាទាំងស្រុង។

**រូបភាព៣៨: ការប្រឈមនឹងការទទួលពិន័យចំពោះទង្វើខុសឆ្គងនានា**




ចំណាំ៖ ០=មិនល្អ ២៥=មិនសូវល្អ ៥០=មធ្យម ៧៥=ល្អ ១០០=ល្អណាស់

## អន្តររដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

អន្តររដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានភាពប្រសើរឡើង។ លទ្ធផលនៃការអង្កេតជាមួយក្រុមប្រឹក្សាបង្ហាញថា៖

- ⇧ ភាពមិនចុះសម្រុងគ្នារវាងរដ្ឋបាលថ្នាក់ក្រោមជាតិមានការថយចុះ។ ប្រសិនបើមានភាពមិនចុះសម្រុងគ្នាកើតឡើង វានឹងត្រូវបានដោះស្រាយប្រកបដោយការពេញចិត្ត។
- ⇧ ផ្អែកលើសូចនាករទាំង៩ គុណភាពនៃការគាំទ្ររបស់ក្រសួងនិងរដ្ឋបាលថ្នាក់ក្រោមជាតិកើនឡើងប្រមាណជា៤%ពីឆ្នាំ២០១១-១៦ និងប្រមាណជា៦%ពីឆ្នាំ២០១៣-១៦។ ក្នុងអត្ថន័យស្ថិតិ វាមានការកើនឡើងគួរឲ្យកត់សម្គាល់ ជាពិសេសការគាំទ្រពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
- ⇧ យោងតាមលទ្ធផលនៃការអង្កេតដែលធ្វើឡើងជាមួយក្រុមប្រឹក្សាបង្ហាញថា ស្ថាប័នផ្សេងទៀតនៅកម្រងរារាំងសកម្មភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- ⇧ ក្រុមប្រឹក្សាយល់ថាពួកគាត់កាន់តែមានឱកាសបង្កើតនូវគំនិតច្នៃប្រឌិត និងស្វ័យភាពថវិកា ព្រមទាំងអាចធ្វើសេចក្តីសម្រេចចិត្តលើការអនុវត្តកិច្ចការអាទិភាពនានារបស់ខ្លួន និងអាចចុះកិច្ចសន្យាជាមួយអ្នកផ្តល់សេវានានាផងដែរ។
- ⇧ ការចែករំលែកព័ត៌មានរវាងរដ្ឋបាលថ្នាក់ក្រោមជាតិមានការកើនឡើង។

## ការបកស្រាយ និងឱកាសសម្រាប់អនុវត្ត

**អភិបាលកិច្ចមូលដ្ឋានមានការកើនឡើងគួរឲ្យកត់សម្គាល់ពីឆ្នាំ២០១៣-១៦។** ការកើនឡើងនេះដោយសារភាពប្រសើរឡើងនៃការផ្តល់សេវា ការឆ្លើយតប ការលើកកម្ពស់ក្រុមជនងាយរងគ្រោះ និងតម្លាភាព។ សន្ទស្សន៍អភិបាលកិច្ចមូលដ្ឋានឆ្នាំ២០១៦ទាបជាងសន្ទស្សន៍នៃការអង្កេតដើមគ្រាឆ្នាំ២០១១ ហើយលទ្ធផលនេះអាចបណ្តាល

មកពីកត្តាខាងក្រៅមួយចំនួន រួមមាន ការបោះឆ្នោតជាតិក្នុងឆ្នាំ២០១៣ និងក្រុមហ៊ុនផ្សេងគ្នាចុះប្រមូលទិន្នន័យ។ និន្នាការ និងលទ្ធផលនៃការអង្កេតផ្តល់នូវភាពពាក់ព័ន្ធសំខាន់ៗមួយចំនួនដូចខាងក្រោម៖

**តារាងទី២: ភាពពាក់ព័ន្ធសំខាន់ៗមួយចំនួននៃការអង្កេតអភិបាលកិច្ចមូលដ្ឋាន**

| សកម្មភាពដែលត្រូវអនុវត្ត | ភស្តុតាង |
|---|---|
| 1. **ការពង្រឹងប្រព័ន្ធដោះស្រាយបណ្តឹង ដោយប្រើវិធីសាស្ត្រមួយដែលជួយជំរុញការដាក់ពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋឲ្យបានសកម្មជាងមុន** តាមរយៈការអនុវត្តយន្តការទំនាក់ទំនងដើម្បីលើកកម្ពស់ការដាក់ពាក្យបណ្តឹង | ប្រជាពលរដ្ឋជាច្រើន (៧០%) ចង់ដាក់ពាក្យបណ្តឹងទៅរដ្ឋបាលមូលដ្ឋានរបស់ខ្លួន ប៉ុន្តែពួកគាត់មិនដែលបានដាក់ពាក្យបណ្តឹង **រូបភាពទី២២**។ ជាមួយគ្នានេះ នីតិវិធីនៃការដោះស្រាយពាក្យ បណ្តឹងនៅមានស្មុគស្មាញ ហើយប្រជាពលរដ្ឋមិនសូវជឿជាក់ថាបណ្តឹងរបស់គាត់នឹងត្រូវបានដោះស្រាយបានល្អ។ |
| 2. **ការលើកកម្ពស់ការប្រឹក្សាយោបល់ក្នុងកិច្ចដំណើរការរៀបចំផែនការ** | ការចូលរួមរបស់ប្រជាពលរដ្ឋ និងការបន្សុីផ្នែកគោលនយោបាយមានការធ្លាក់ចុះ។ ចំនួនប្រជាពលរដ្ឋដែលធ្លាប់បញ្ចេញមតិក្នុងកិច្ចប្រជុំធ្វើផែនការ និងធ្លាប់គិតថាពួកគាត់ជាផ្នែកដ៏សំខាន់មួយនៃកិច្ចប្រជុំមានការធ្លាក់ចុះ។ ករណីនេះអាចនឹងបណ្តាលឲ្យមានការយល់ផ្សេងគ្នារវាងអ្វីដែលប្រជាពលរដ្ឋគិតថាសំខាន់ និងអ្វីដែលក្រុមប្រឹក្សាបានអនុវត្ត ហើយគិតថាសំខាន់។ |
| 3. **រៀបចំនីតិវិធី និងបណ្តុះបណ្តាលក្រុមប្រឹក្សាពីការទំនាក់ទំនងជាមួយប្រជាពលរដ្ឋនៅមូលដ្ឋាន** | ក្រុមប្រឹក្សាធ្លាប់ទាក់ទងប្រជាពលរដ្ឋមូលដ្ឋានចំនួនពី២-៣ដងក្នុងមួយឆ្នាំ ច្រើនជាងប្រជាពលរដ្ឋមូលដ្ឋានទាក់ទងទៅក្រុមប្រឹក្សាវិញ **រូបភាពទី២៦**។ ក្រុមប្រឹក្សាត្រូវបានទទួលស្គាល់បន្ថែមទៀតថាជាអ្នកដែលជួយដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋនៅមូល-ដ្ឋាន។ |
| 4. **ការការពារនិងគាំទ្រក្រុមជនងាយរងគ្រោះ ដោយវិធីសាស្ត្រសមស្រប** ដូចជាការរៀបចំនូវកម្មវិធីជាក់លាក់ដើម្បីលើកកម្ពស់ការចូលរួមរបស់យុវជននៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | ប្រជាពលរដ្ឋយល់ថាតម្រូវការរបស់ស្ត្រី និងកុមារត្រូវបានការពារ និងគាំទ្របានប្រសើរជាងតម្រូវការរបស់យុវជន គ្រួសារក្រីក្រ និងក្រុមជនជាតិដើមភាគតិច **រូបភាពទី២៤**។ |
| 5. **ការបង្កើតប្រព័ន្ធគណនេយ្យភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្តោតលើការបំពេញការងារ និងការអវត្តមានពីការងាររបស់មន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិ** | វិធានការនៃការដាក់វិន័យមិនសូវត្រូវបានអនុវត្ត ពិសេសចំពោះករណីអវត្តមានរបស់មន្ត្រីពីការងារ និងការបំពេញការងារមិនបានល្អរបស់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ **រូបភាពទី៣៧**។ |

# 1. សេចក្តីផ្តើម

## 1.1 សាវតា

ការលើកកម្ពស់អភិបាលកិច្ចជាផ្នែកដ៏សំខាន់មួយនៃកំណែទម្រង់អភិបាលកិច្ចមូលដ្ឋានរបស់ប្រទេសកម្ពុជា។ របាយការណ៍នេះរៀបរាប់ពីនិន្នាការអភិបាលកិច្ចមូលដ្ឋាន ពិសេសទស្សនៈរបស់ប្រជាពលរដ្ឋពីអភិបាលកិច្ចមូលដ្ឋានដោយប្រៀបធៀបនឹងលទ្ធផលនៃការអង្កេតឆ្នាំ២០១១ ឆ្នាំ២០១៣ និងឆ្នាំ២០១៦[2]។

ការអង្កេតអភិបាលកិច្ចដើមគ្រាឆ្នាំ២០១១ រៀបរាប់លម្អិតអំពីវិធីសាស្ត្រ និងដំណើរការនៃការបង្កើតសន្ទស្សន៍អភិបាលកិច្ចមូលដ្ឋាន។

រូបភាពទី៩: ក្របខ័ណ្ឌអភិបាលកិច្ច




### 1.1.1 អភិបាលកិច្ចមូលដ្ឋាន

អភិបាលកិច្ចមូលដ្ឋានត្រូវបានឲ្យនិយមន័យថា "របៀបដែលសិទ្ធិ ឬអំណាចត្រូវបានប្រើប្រាស់"។ យោងតាមឯកសារផ.អ.៣ទី១ អភិបាលកិច្ចមូលដ្ឋានត្រូវបានរៀបជាគំរូមួយដែលបានដាក់បញ្ចូលនូវដំណើរការចំនួន៣ (ការចូលរួមរបស់ប្រជាពលរដ្ឋ តម្លាភាព និងគណនេយ្យភាព) និងសមិទ្ធផលចំនួន៤ (ការការពារសិទ្ធិរបស់ក្រុមជនងាយរងគ្រោះ ការឆ្លើយតប ការបន្សុីគ្នាផ្នែកគោលនយោបាយ និងការផ្តល់សេវា)។[3] ជំពូកនីមួយៗសង្ខេប វិធីសាស្ត្រនៃការអង្កេត ដែនកំណត់ និងរង្វាស់អភិបាលកិច្ចផ្សេងទៀតដែលមានក្នុងប្រទេសកម្ពុជា។

## 1.2 វិធីសាស្ត្រ

ទិន្នន័យនៃការអង្កេតនេះត្រូវបានប្រមូលដោយក្រុមហ៊ុនស្រាវជ្រាវឯករាជ្យមួយ ផ្អែកលើកម្រងសំណួរចំនួន៤ប្រភេទផ្សេងៗគ្នា សម្រាប់ប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងគណៈអភិបាលនិងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ហើយដែលមានសំណួរចំនួនសរុបប្រមាណជា២៥០។ ការអង្កេតនេះធ្វើឡើងដើម្បីៈ (១). បង្កើត សូចនាករដោយផ្អែកលើក្របខ័ណ្ឌអភិបាលកិច្ចរបស់ផ.អ.៣ (២). យកលទ្ធផលនៃការអង្កេតនេះធ្វើជាតំណាង ទូទាំងប្រទេស (៣). ស្ទាបស្ទង់មតិប្រជាពលរដ្ឋ ក្រុមប្រឹក្សា និងគណៈអភិបាល និង (៣). គ្របដណ្តប់

---

[2] របាយការណ៍ពិនិត្យមើលថាតើ (១). ទស្សនៈរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ទាំងនៅតំបន់ទីក្រុង និងជនបទ (២). ទស្សនៈរបស់បុរស និងស្ត្រី និង (៣). ទស្សនៈប្រជាជនក្រីក្រដែលស្ថិតក្នុងទីតាំងបច្ចុភាគទីមួយ និងប្រជាជនដែលមានជីវភាពធូរធារដែលស្ថិតក្នុងទីតាំងបច្ចុភាគទី៣ មានភាពខុសគ្នាដែរ ឬទេក្នុងអត្ថន័យស្ថិតិ។

[3] និយមន័យផ្សេងទៀតនៃអភិបាលកិច្ចមូលដ្ឋាន រួមមាន "ការប្រើប្រាស់អំណាចនយោបាយ និងការប្រើប្រាស់ធនធានរបស់ស្ថាប័នដើម្បីចាត់ចែងកិច្ចការ និងបញ្ហាសង្គម" (World Bank, 1991) "ការអនុវត្ត និងប្រព័ន្ធគ្រប់គ្រងដែលអំណាចត្រូវបានប្រើប្រាស់ (World Bank Institute)" "គុណតម្លៃ គោលនយោបាយ និងប្រព័ន្ធគ្រប់គ្រងដែលសង្គមស៊ីវិលគ្រប់គ្រងសេដ្ឋកិច្ច នយោបាយ និងកិច្ចការសង្គម តាមរយៈទំនាក់ទំនងផ្ទៃក្នុង និងផ្ទៃក្រៅជាមួយបរទេស សង្គមស៊ីវិល និងក្រុមហ៊ុនឯកជន" (UNDP)

រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ ក្របខ័ណ្ឌសំណាកបានរៀបចំឡើងដើម្បីធ្វើការជ្រើសរើសដោយ ចៃដន្យនូវអ្នកផ្តល់សម្ភាសន៍ដែលអាចធ្វើជាតំណាង។ អ្នកផ្តល់សម្ភាសន៍ផ្សេងគ្នាត្រូវបានជ្រើសរើសសម្រាប់ការអង្កេតឆ្នាំ២០១១ ឆ្នាំ២០១៣ និងឆ្នាំ២០១៦ ទោះបីជាភូមិ និងចំនួនអ្នកផ្តល់សម្ភាសន៍តាមភូមិនីមួយៗដូចគ្នាក៏ដោយ។[4] ការអង្កេតឆ្នាំ២០១៦ធ្វើឡើងដោយមានអ្នកផ្តល់សម្ភាសន៍ចំនួន២.១១៣នាក់ រួមមានប្រជាពលរដ្ឋតំណាងគ្រួសារចំនួន១.៣៤៤នាក់ ក្រុមប្រឹក្សាចំនួន៧១៩រូប និង គណៈអភិបាលចំនួន៥០រូប។ ទន្ទឹមនេះ តំបន់ភូមិសាស្ត្រទាំង៥ ត្រូវបានជ្រើសរើស ដោយរួមមានភូមិចំនួន១៩២ រដ្ឋបាលឃុំ សង្កាត់ចំនួន៩៦ រដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន ៤៨ នៅក្នុងរាជធានី ខេត្តចំនួន១៣។ ក្របខ័ណ្ឌសំណាកនៃការអង្កេតនេះមានបង្ហាញក្នុង**តារាងទី៣**។

### 1.2.1 ដែនកំណត់នៃការអង្កេត

ជាទូទៅ គ្រប់ការអង្កេតទាំងអស់តែងតែមានដែនកំណត់។ ការអង្កេតអភិបាលកិច្ច មូលដ្ឋានធ្វើឡើង ដើម្បីស្ទាបស្ទង់មតិ និងកត់ត្រានូវអ្វីដែលប្រជាពលរដ្ឋបានលើកឡើង ជាជាងអ្វីដែលពួកគាត់បានធ្វើជាក់ស្តែង។ ទន្ទឹមនេះ អ្នកផ្តល់សម្ភាសន៍អាចនឹងមិនយល់សំណួរច្បាស់ ឬឆ្លើយសំណួរមិនបានអស់ពីចិត្ត។ ការសម្ភាសន៍ជាដំណើរការទំនាក់ទំនង ដូច្នេះចម្លើយរបស់អ្នកផ្តល់សម្ភាសន៍គឺអាស្រ័យលើវិធីសាស្ត្រនៃការសួរ ដូចជាការប្រើប្រាស់ពាក្យពេជន៍ ការរៀបសំណួរសម្រាប់សួរ និងកត្តាផ្សេងៗទៀត។[5] ការអង្កេតនេះអាចមានភាពលំអៀងមួយចំនួន ព្រោះអ្នកផ្តល់សម្ភាសន៍អាចនឹងមាននិន្នាការជ្រើសរើសយកសំណួរកណ្តាល។ ចំពោះការសម្ភាសន៍ជាមួយក្រុមប្រឹក្សា និង

**តារាងទី៣: ក្របខ័ណ្ឌសំណាក**

| សំណាក | 2011 | 2013 | 2016 |
|---|---|---|---|
| 1. ចំនួនអ្នកផ្តល់សម្ភាសន៍ជាតំណាងគ្រួសារ | 1,344 | 1,345 | 1,344 |
| 2. % នៃស្ត្រី | 62% | 64% | 64% |
| 3. អាយុជាមធ្យម | 45.47 | 42.34 | 43.71 |
| 4. ចំនួនសមាជិកគ្រួសារជាមធ្យម | 5.36 | 4.50 | 4.52 |
| 5. មុខងារនៅក្នុងគ្រួសារ | | | |
| 5.1. % ជាមេគ្រួសារ | 52% | 45% | 45% |
| 5.2. % ជាប្រពន្ធ | 14% | 20% | 38.30 |
| 6. ស្ថានភាពគ្រួសារ (៤ ប្រភេទ) | | | |
| 6.1. % ជាអ្នករៀបការ ឬរស់នៅជាមួយគ្នា | 79% | 74% | 74% |
| 6.2. % ជាអ្នកនៅលីវ | 8% | 12% | 10% |
| 7. កម្រិតវប្បធម៌ | | | |
| 7.1. % មិនបានចូលរៀន | 20% | 15% | 16% |
| 7.2. % បញ្ចប់ថ្នាក់វិទ្យាល័យ ឬខ្ពស់ជាងនេះ | 7% | 10% | 11% |
| 8. មុខរបរសំខាន់ | | | |
| 8.1. % កសិករ | 47% | 41% | 40% |
| 8.2. % កម្មករ ឬស៊ីឈ្នួល | 3% | 6% | 3% |
| 8.3. % មេផ្ទះ | 6% | 9% | 9% |
| 9. ប្រភពប្រាក់ចំណូលសំខាន់ៗ | | | |
| 9.1. វិស័យកសិកម្ម | 48% | 42% | 38% |
| 9.2. ពាណិជ្ជកម្ម | 31% | 28% | 25% |
| 9.3. ប្រាក់បៀវត្សរ៍ | 7% | 13% | 17% |
| 9.4. ចំណាកស្រុក | 6% | 9% | 8% |
| 10. ម្ចាស់កម្មសិទ្ធិ | | | |
| 10.1. គង់ | 74% | 69% | 70% |
| 10.2. យានយន្ត (ម៉ូតូ ឡាន) | 66% | 70% | 77% |
| 10.3. ម៉ាស៊ីនបូមទឹក | 19% | 22% | 19% |
| 10.4. ទូរទស្សន៍ | 76% | 80% | 80% |

[4] នេះជាការជ្រើសរើសសំណាកដែលអនុវត្តទៅតាមគោលការណ៍នៃការអង្កេតដើមគ្រា។

[5] ការពន្យល់បន្ថែមសូមមើល Bertrand and Mullainathan, 2001.

គណៈអភិបាលវិញ អ្នកផ្តល់សម្ភាសប្រហែលជាមិនអាចកំណត់នូវភាពខុសគ្នារវាងតួនាទី និងមុខងារនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ និងក្រសួងស្ថាប័នថ្នាក់ជាតិ។ ម្យ៉ាងទៀត សំណួរមួយចំនួនដែលពាក់ព័ន្ធនឹងការផ្តល់សេវាគួរតែសួរនៅកន្លែងផ្តល់សេវាតែម្តង និងបន្ទាប់ពីទទួលសេវាភ្លាមៗ ព្រោះអ្នកផ្តល់សម្ភាសអាចរំលឹកពីបទពិសោធន៍នៃការទទួលសេវាបានល្អ។

ជាលទ្ធផល ទិន្នន័យនៃការអង្កេតអភិបាលកិច្ចមូលដ្ឋានគួរយកទៅធ្វើការបកស្រាយដោយប្រុងប្រយ័ត្ន ព្រោះការអង្កេតអភិបាលកិច្ចមូលដ្ឋានឆ្នាំ២០១៣បានធ្វើឡើងពីខែវិច្ឆិកាដល់ខែធ្នូ ប្រមាណជា២-៣ខែ បន្ទាប់ពីមានការបោះឆ្នោតជាតិដែលមានលក្ខណៈប្រកួតប្រជែងខ្លាំង។ ព្រឹត្តិការណ៍នេះអាចប៉ះពាល់ដល់ការបញ្ចេញមតិរបស់អ្នកផ្តល់សម្ភាស និងតម្លាភាព។

### 1.2.2 សន្ទស្សន៍

អភិបាលកិច្ចមូលដ្ឋានត្រូវបានវាស់វែងដោយប្រើសន្ទស្សន៍នៃទស្សនៈរបស់ប្រជាពលរដ្ឋ។ សូចនាករនេះបានបង្កើតឡើងដោយការផ្គុំគ្នានូវអថេរមួយចំនួនតាមគំរូមូលដ្ឋានដែលមានស្រាប់។ ជាលទ្ធផល សន្ទស្សន៍បង្កើតឡើងដោយការផ្គុំលក្ខខុសគ្នាឲ្យទៅជារង្វាស់ ដើម្បីវាស់ទស្សនៈផ្សេងៗគ្នាដែលមិនអាចវាស់វែងបានដោយអថេរតែមួយ ដូចជា "អភិបាលកិច្ចមូលដ្ឋាន ឬគណនេយ្យភាព"។ សន្ទស្សន៍ត្រូវបានបង្កើតឡើងដោយ៖ (១). បង្កើតកូដចម្លើយរបស់សំណួរនីមួយៗឲ្យទៅជាមាត្រដ្ឋានរួមមួយដែលមានតម្លៃពី0ដល់១០០ (២). គណនាតម្លៃស្ថិតិសម្រាប់សូចនាករនីមួយៗ (មធ្យម និងកំហុសបទដ្ឋាន) (៣). ប្រើទម្ងន់ស្មើៗគ្នា និងកំហុសបទដ្ឋាននីមួយៗ និង (៤). បូកឡើងនូវផលបូកនៃមធ្យមសម្រាប់សូចនាករនីមួយៗ និងគុណជាមួយនឹងទម្ងន់ដើម្បីបង្កើតសន្ទស្សន៍។

**រូបភាពទី១០: អនុសន្ទស្សន៍អភិបាលកិច្ចមូលដ្ឋាន**

**សន្ទស្សន៍ការផ្តល់សេវា (១៩)**
- គុណភាពសេវា (១៨)
- ប្រជាពលរដ្ឋចង់តវ៉ាពីការផ្តល់សេវា (១)

**សន្ទស្សន៍ការបន្សាំផ្នែកគោលនយោបាយ (៦)**
- ការបន្សាំផ្នែកគោលនយោបាយ (៤)
- ទំនាក់ទំនងស្ថិតិរវាងតម្រូវការអាទិភាពរបស់ប្រជាជន និងតម្រូវការអាទិភាពរបស់ក្រុមប្រឹក្សា (២)

**សន្ទស្សន៍ការឆ្លើយតប (១៣)**
- ប្រជាពលរដ្ឋស្គាល់យន្តការដោះស្រាយបណ្តឹងយ៉ាងហោចណាស់ចំនួន១ (២)
- ការពេញចិត្តនឹងដំណោះស្រាយរបស់បណ្តឹង (៨)
- ការឆ្លើយតបរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ (២)
- ឱកាសដែលប្រជាពលរដ្ឋអាចតវ៉ាបានប្រសិនបើមានការមិនពេញចិត្តនឹងសេវា (១)

**សន្ទស្សន៍ក្រុមជនងាយរងគ្រោះ (២៤)**
- ការវាយតម្លៃរបស់ប្រជាពលរដ្ឋលើការការពារក្រុមជនងាយរងគ្រោះនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ (១០)
- អនុបាតស្ត្រី/បុរស និងអ្នកក្រ/អ្នកមានជីវភាពធូរធារ (១៤)

**ការចូលរួមរបស់ប្រជាពលរដ្ឋ (៣២)**
- កម្រិតនៃទំនាក់ទំងក្រៅផ្លូវការរបស់ប្រជាពលរដ្ឋនិងក្រុមប្រឹក្សា (៤)
- កម្រិតដែលប្រជាពលរដ្ឋបានចូលរួមប្រជុំ និងបញ្ចេញមតិក្នុងកិច្ចប្រជុំផ្លូវការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (១២)
- ការវាយតម្លៃ៖ សារៈសំខាន់នៃកិច្ចប្រជុំផ្លូវការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (៨)
- ការចូលរួម កិច្ចសហប្រតិបត្តិការណ៍ និងប្រសិទ្ធិភាពរបស់អង្គការសង្គមស៊ីវិលនៅមូលដ្ឋាន (៨)

**សន្ទស្សន៍តម្លាភាព (១៦)**
- ប្រជាពលរដ្ឋទាមទារចង់បានព័ត៌មាន (២)
- ប្រជាពលរដ្ឋអាចស្វែងរកព័ត៌មានបាន (១០)
- ប្រជាពលរដ្ឋមានការពេញចិត្តនឹងព័ត៌មានដែលបានផ្តល់ឲ្យ (២)
- ប្រជាពលរដ្ឋទទួលបានព័ត៌មានពីតម្លៃត្រឹមត្រូវរបស់សេវា (២)

**សន្ទស្សន៍គណនេយ្យភាព (១០)**
- ការវាយតម្លៃរបស់ប្រជាពលរដ្ឋពីការប្រឈមនឹងការដាក់ពិន័យចំពោះទង្វើខុសឆ្គងរបស់មន្ត្រីរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ (១០)

**សន្ទស្សន៍អន្តររដ្ឋបាល (៤២)**
- ភាពញឹកញាប់នៃការមិនយល់ស្របគ្នារវាងរដ្ឋបាលថ្នាក់ក្រោមជាតិ (៤)
- ការពេញចិត្តនឹងដំណោះស្រាយនៃការមិនយល់ស្របគ្នារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (៤)
- គុណភាពនៃការគាំទ្រទៅរដ្ឋបាលថ្នាក់ក្រោមជាតិ (៩)
- ការវាយតម្លៃរបស់ក្រុមប្រឹក្សាលើស្វ័យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (១៧)
- ការវាយតម្លៃរបស់ក្រុមប្រឹក្សាលើការទទួលបានព័ត៌មានអន្តររដ្ឋបាល (៨)

ចំណាំ៖ ចំនួនសូចនាករនៃអនុសន្ទស្សន៍មាននៅក្នុងរង្វង់ក្រចកខាងលើ។

ការគណនាសន្ទស្សន៍ធ្វើឡើងតាមលំដាប់ **(រូបភាពទី១០)** ដោយអថេរពាក់ព័ន្ធត្រូវបានបូកបញ្ចូលគ្នាដើម្បីបង្កើតអនុសូចនាករ ហើយអនុសូចនាករបូកបញ្ចូលគ្នាដើម្បីបង្កើតជាសន្ទស្សន៍។ គ្រប់ករណីទាំងអស់ទម្ងន់ដូចគ្នាៗត្រូវបានប្រើ។

### 1.2.3 មាត្រដ្ឋានតាង

សំណួរជាច្រើននៃការអង្កេតអភិបាលកិច្ចមូលដ្ឋានគឺប្រើមាត្រដ្ឋានតាងពី១ដល់៥ ហើយសំណួរទាំងនេះប្រើសម្រាប់ស្ទាបស្ទង់កម្រិតនៃការយល់ឃើញរបស់អ្នកផ្តល់សម្ភាស។ ចម្លើយសម្រាប់សំណួរនីមួយៗត្រូវបានប្តូរទៅជាលេខដែលស្ថិតលើមាត្រដ្ឋានពី០ដល់១០០។

## 1.3 សេចក្តីសន្និដ្ឋាន

សន្ទស្សន៍អភិបាលកិច្ចមូលដ្ឋានមានគោលបំណងស្ទាបស្ទង់ពីការផ្លាស់ប្តូរនៃអភិបាលកិច្ចមូលដ្ឋាន។ ដើម្បីទាញបានជាសេចក្តីសន្និដ្ឋាន តេស្តស្ថិតិត្រូវបានប្រើប្រាស់ដើម្បីធ្វើការប្រៀបធៀបមធ្យមភាគនៃសូចនាករ និងសន្ទស្សន៍ ព្រមទាំងរង្វាស់របស់វា (តាមរយៈប្រើប្រាស់កំហុសបទដ្ឋាន និងកម្រិតនៃទំនុកចិត្ត៩៥% ដែលមានចន្លោះគម្លាតប្រមាណជា ±១.៩៦ x កំហុសបទដ្ឋាន)។ សេចក្តីសន្និដ្ឋានត្រូវបានតេស្តមើលថាតើសូចនាករ ឬតម្លៃសន្ទស្សន៍មានការកើនឡើង និងធ្លាក់ចុះគួរឲ្យកត់សម្គាល់ក្នុងអត្ថន័យស្ថិតិ ពីឆ្នាំ២០១១ ទៅឆ្នាំ២០១៣ និងឆ្នាំ២០១៦។

ទោះបីជាការអង្កេតអភិបាលកិច្ចមូលដ្ឋានបន្តធ្វើការកត់ត្រានូវការផ្លាស់ប្តូរនៃអភិបាលកិច្ចមូលដ្ឋានក៏ដោយ ការផ្លាស់ប្តូរទាំងនេះមិនអាចសន្និដ្ឋានថាជាលទ្ធផលរបស់ផ.អ.៣ ឬកិច្ចអន្តរាគមន៍ជាក់លាក់ណាមួយរបស់ផ.អ.៣ ទាំងស្រុងបាននោះទេ។ ទន្ទឹមនេះ ការអង្កេតដើមគ្រាបានធ្វើឡើងដោយក្រុមហ៊ុនមួយ ដែលខុសពីក្រុមហ៊ុនដែលបានប្រមូលទិន្នន័យសម្រាប់ការអង្កេតបន្តទី១និងទី២។ ទិន្នន័យនៃការអង្កេតដើមគ្រាមានភាពមិនប្រក្រតីមួយចំនួន ដែលនាំឲ្យប៉ះពាល់ដល់គុណភាពរបស់ទិន្នន័យ។ ជារួម មានកត្តា២យ៉ាងដែលធ្វើឲ្យ លទ្ធផលនៃការអង្កេតនេះមិនអាចឆ្លុះបញ្ចាំងពីអភិបាលកិច្ចមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលកត្តាទាំងនោះរួមមានការបោះឆ្នោតជាតិ និងគុណភាពនៃទិន្នន័យអង្កេតដើមគ្រានិងការអង្កេតបន្តទាំង២លើក។

**រូបភាពទី១១: សន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយរបស់អង្គការតម្លាភាពអន្តរជាតិ**




**រូបភាពទី១២: សន្ទស្សន៍អភិបាលកិច្ចរបស់ស្ថាប័នធនាគារពិភពលោក**




ចំណាំ: កម្រិតសន្ទស្សន៍របស់ TI គឺ ០ដល់១០០ ហើយកម្រិតសន្ទស្សន៍របស់វិទ្យាស្ថានធនាគារពិភពលោក គឺ ±២.៥

## 1.4 ការអង្កេតផ្សេងទៀត និងនិន្នាការនៃអភិបាលកិច្ច

ការប្រៀបធៀបការអង្កេតអភិបាលកិច្ចជាលក្ខណៈអន្តជាតិអាចជួយវាស់វែងអភិក្រមអភិបាលកិច្ច

នៅកម្ពុជា[6]។ កម្មវិធីវាយតម្លៃ "បញ្ហាអភិបាលកិច្ច" របស់ស្ថាប័នធនាគារពិភពលោក ប្រហែលជាការវាយតម្លៃដែលលេចធ្លោជាងគេនៅទូទាំងប្រទេស។ វាបង្ហាញពីបម្រែបម្រួលទៅរកភាពល្អប្រសើរ (**រូបភាពទី១២**) ចាប់ពីឆ្នាំ ២០១០-១៥ និងមានការធ្លាក់ចុះនៅមុំពេលបោះឆ្នោតឆ្នាំ២០១៣។ សន្ទស្សន៍នេះផ្អែកទៅលើចំណុចទាំង៦ (**រូបភាពទី១៣**) ដែលបង្ហាញពីភាពប្រសើរឡើងនូវស្ថេរភាពនយោបាយ ប្រសិទ្ធិភាពនៃការគ្រប់គ្រង និងនីតិរដ្ឋ។ សន្ទស្សន៍នៃការបញ្ចេញមតិ និងគុណភាពនៃលិខិតបទដ្ឋានគតិយុត្តិបានធ្លាក់ចុះក្នុងកំឡុងពេលកម្មវិធីជាតិ។ សន្ទស្សន៍នៃការយល់ដឹងអំពីអំពើពុករលួយដែលវាយតម្លៃដោយអង្គការតម្លាភាពអន្តរជាតិបានបង្ហាញថាមានការប្រែប្រួលតិចតួច តែលទ្ធផលទាំងនេះផ្តោតតែលើថ្នាក់ជាតិតែប៉ុណ្ណោះ ខណៈពេលដែលការអង្កេតរបស់យើងផ្តោតលើរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

**រូបភាពទី១៣: សន្ទស្សន៍ទាំង៦របស់វិទ្យាស្ថានធនាគារពិភពលោក**




[6] ដូចដែលបានបង្ហាញនៅក្នុងរបាយការណ៍ឆ្នាំ២០១៣របស់យើងរវាងខែមករា និងខែវិច្ឆិកាឆ្នាំ២០១៣ ការអង្កេតរបស់វិទ្យាស្ថាន International Republican Institute បានបង្ហាញថាមានការធ្លាក់ចុះគួរឲ្យកត់សម្គាល់នូវទស្សនៈរបស់ប្រជាពលរដ្ឋថា "ប្រទេសកម្ពុជាកំពុងឆ្ពោះទៅមុខក្នុងផ្លូវត្រូវ"

# 2. ការផ្តល់សេវា

## 2.1 និន្នាការនៃការផ្តល់សេវា

ក្នុងឆ្នាំ២០១៦ ប្រជាពលរដ្ឋពេញចិត្តនឹងសេវា ដែលទទួលបានជាងក្នុងឆ្នាំ២០១១ឬឆ្នាំ២០១៣។ និន្នាការនេះបង្ហាញថាការពេញចិត្តរបស់ប្រជាពលរដ្ឋនឹងផ្តល់សេវា ពីឆ្នាំ២០១១-១៣ និងពីឆ្នាំ២០១៣-១៦ មានការកើនឡើង ដែលជាការកើនឡើងគួរឲ្យកត់សម្គាល់ ក្នុងអត្ថន័យស្ថិតិ ។ ទិន្នន័យលម្អិតមានបង្ហាញក្នុង**តារាងទី៤**៖

រូបភាពទី១៤: ការពេញចិត្តនឹងការផ្តល់សេវា




- ការផ្តល់សេវាមានភាពល្អប្រសើរឡើង ទាំងនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ពីឆ្នាំ២០១១-១៦ និងពីឆ្នាំ២០១៣-១៦
- ការកើនឡើងមានលក្ខណៈគួរឲ្យកត់សម្គាល់ ហើយគ្របដណ្តប់លើសេវាទាំងអស់ លើកលែងតែការកសាងផែនការអភិវឌ្ឍន៍ និងការកសាងផ្លូវ
- បើប្រៀបធៀបនឹងការអង្កេតដើមគ្រា ការផ្តល់សេវានៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ មានភាពប្រសើរឡើងជាងនៅរដ្ឋបាលឃុំ សង្កាត់
- ចាប់តាំងពីឆ្នាំ២០១១ (ការអង្កេតមូលដ្ឋាន) ការកើនឡើងខ្ពស់បំផុតនៃការពេញចិត្ត គឺទាក់ទិនទៅនឹងការគ្រប់គ្រងសំណល់រឹង និងការអភិវឌ្ឍន៍ជំនួញនៅថ្នាក់ស្រុក
- នៅក្នុងឆ្នាំ២០១៦ ៨៦%នៃប្រជាពលរដ្ឋមិនចង់តវ៉ានឹងការផ្តល់សេវានោះទេ ដែលលទ្ធផលនេះអាចបង្ហាញថាប្រពលរដ្ឋភាគច្រើនមានការពេញចិត្តជាមួយនឹងការផ្តល់សេវា។

រូបភាពទី១៥: ការពេញចិត្តនឹងការផ្តល់សេវា (២០១៦)




ចំណាំ: 0=មិនល្អ ២៥=មិនសូវល្អ ៥0=មធ្យម ៧៥=ល្អ ១00=ល្អណាស់

## 2.2 តើសេវាណាមួយដែលប្រជាពលរដ្ឋពេញចិត្តជាងគេក្នុងឆ្នាំ២០១៦?

សន្ទស្សន៍នៃការអង្កេតនេះ ផ្អែកទៅលើសេវាចំនួន១៧។ ទិន្នន័យក្នុង**តារាងទី៤**បង្ហាញថា ប្រជាពលរដ្ឋមានការពេញចិត្តចំពោះមុខងារសំខាន់ៗដែលផ្តល់ដោយរដ្ឋបាលឃុំ សង្កាត់ ពិសេសការងារអត្រានុកូដ្ឋាន និងការដោះស្រាយជម្លោះ។

### តារាងទី៤ : ទិន្នន័យនៃការពេញចិត្តនឹងការផ្តល់សេវារបស់រដ្ឋក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់

| បរិយាយ | តម្លៃមធ្យម | | | បម្រែបម្រួលជា% | | គួរឲ្យកត់សម្គាល់ | |
|---|---|---|---|---|---|---|---|
| | 2011 | 2013 | 2016 | 2011-16 | 2013 -16 | 2011-16 | 2013 -16 |
| **ការពេញចិត្តនឹងការផ្តល់សេវារបស់រដ្ឋបាលឃុំ សង្កាត់** | **54.62** | **49.57** | **55.99** | **2.51%** | **12.97%** | ✓ | ✓ |
| ការសាងសង់ផ្លូវ | 56.47 | 49.65 | 53.84 | -4.66% | 8.45% | ✓ | ✓ |
| ការសាងសង់ប្រព័ន្ធស្រោចស្រព | 44.86 | 41.09 | 48.07 | 7.15% | 16.98% | ✓ | ✓ |
| ការកសាងផែនការឃុំ/សង្កាត់ | 60.33 | 53.92 | 58.75 | -2.62% | 8.96% | x | ✓ |
| ការលើកកម្ពស់អនាម័យ | 53.99 | 51.01 | 57.22 | 5.99% | 12.18% | ✓ | ✓ |
| ការសម្របសម្រួលនិងដោះស្រាយជម្លោះ | 59.96 | 57.24 | 60.70 | 1.23% | 6.03% | ✓ | ✓ |
| ការផ្គត់ផ្គង់ទឹក | 50.92 | 49.52 | 57.75 | 13.41% | 16.64% | ✓ | ✓ |
| ការគ្រប់គ្រងកាកសំណល់រឹង | 46.99 | 41.45 | 50.35 | 7.16% | 21.47% | ✓ | ✓ |
| ការងារអត្រានុកូដ្ឋាន | 73.46 | 63.96 | 67.72 | -7.82% | 5.87% | ✓ | ✓ |
| ការអភិវឌ្ឍន៍ជំនួញ | 44.60 | 38.25 | 49.53 | 11.05% | 29.50% | ✓ | ✓ |
| **ការពេញចិត្តនឹងការផ្តល់សេវារបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ** | **53.72** | **48.64** | **56.52** | **5.21%** | **16.19%** | ✓ | ✓ |
| ការសាងសង់ផ្លូវ | 57.65 | 52.39 | 57.05 | -1.04% | 8.90% | x | ✓ |
| ការសាងសង់ប្រព័ន្ធធារាសាស្ត្រ | 47.71 | 44.42 | 51.92 | 8.83% | 16.87% | ✓ | ✓ |
| ការរៀបចំផែនការអភិវឌ្ឍន៍ | 62.08 | 53.54 | 59.83 | -3.63% | 11.75% | x | ✓ |
| ការលើកកម្ពស់អនាម័យ | 56.27 | 52.29 | 58.63 | 4.18% | 12.12% | ✓ | ✓ |
| ការសម្របសម្រួលនិងដោះស្រាយជម្លោះ | 60.74 | 56.55 | 61.23 | 0.80% | 8.28% | ✓ | ✓ |
| ការផ្គត់ផ្គង់ទឹក | 53.14 | 49.90 | 59.32 | 11.63% | 18.87% | ✓ | ✓ |
| ការគ្រប់គ្រងសំណល់រឹង | 48.34 | 40.83 | 52.77 | 9.16% | 29.26% | ✓ | ✓ |
| ការបង្កើត និងពង្រីកមុខរបរ | 43.81 | 39.20 | 51.39 | 17.31% | 31.10% | ✓ | ✓ |
| **% នៃប្រជាពលរដ្ឋដែលមិនមានបំណងប្តឹងតវ៉ា** | **84.97** | **76.06** | **85.60** | **0.74%** | **12.54%** | ✓ | ✓ |
| សរុប | 64.44 | 58.09 | 66.04 | 2.48% | 13.68% | ✓ | ✓ |

ចំណាំ៖ "គួរឲ្យកត់សម្គាល់" វាស់វែងអំពីថាតើការកើនឡើង ឬការថយចុះរវាងឆ្នាំទាំង២មានភាពគួរឲ្យកត់សម្គាល់ដែល ឬទេនៅក្នុងកម្រិតនៃការជឿទុកចិត្ត៩៥%។ សូមកត់ចំណាំថា ការវាយតម្លៃការពេញចិត្ត គឺគិតលើកម្រិតពី0ដល់១០០ (Likert Scale) ដោយមានកម្រិត 0=មិនល្អ ២៥=មិនសូវល្អ ៥0=មធ្យម ៧៥=ល្អ ១០០=ល្អណាស់

# 3. ការបន្ស៊ីផ្នែកគោលនយោបាយ

## 3.1 និន្នាការនៃការបន្ស៊ីផ្នែកគោលនយោបាយ

ការបន្ស៊ីផ្នែកគោលនយោបាយរៀបរាប់ថា តើតម្រូវការអាទិភាពនិងសកម្មភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្លុះបញ្ចាំងពីតម្រូវការអាទិភាពរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនកម្រិតណា ហើយថាតើរដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តអ្វីដែល "ត្រឹមត្រូវ" ហើយតើគេកំពុងតែអនុវត្តតាមគោលការណ៍ដែរ ឬទេ?

**យោងទៅតាមសន្ទស្សន៍នៃការបន្ស៊ីផ្នែកគោលនយោបាយ ការបន្ស៊ីតម្រូវការអាទិភាពរបស់ឃុំ សង្កាត់ និងក្រុង ស្រុក ជាមួយនឹងតម្រូវការអាទិភាពរបស់ប្រជាពលរដ្ឋមានការធ្លាក់ចុះចាប់តាំងពីឆ្នាំ២០១១។** វាមានការធ្លាក់ចុះគួរឲ្យកត់សម្គាល់ក្នុងអត្ថន័យស្ថិតិពីឆ្នាំ២០១១-១៦ ប៉ុន្តែមិនមានការធ្លាក់ចុះគួរឲ្យកត់សម្គាល់ទេពីឆ្នាំ២០១៣-១៦ ។វិធីសាស្ត្រ២យ៉ាងដែលបានប្រើប្រាស់ ដើម្បីវាយតម្លៃអំពីការបន្ស៊ីផ្នែកគោលន-យោបាយៈ (១). ការសម្ភាសផ្ទាល់ជាមួយប្រជាពលរដ្ឋមូលដ្ឋាន (២). ការប្រៀបធៀបតម្រូវការអាទិភាពរបស់ប្រជាពលរដ្ឋ ទៅនឹងតម្រូវការអាទិភាពដែលក្រុមប្រឹក្សាបានលើកឡើង។

រូបភាពទី១៦: សន្ទស្សន៍និន្នាការនៃការបន្ស៊ីគោលនយោបាយ




ចំណាំៈ សន្ទស្សន៍មាត្រដ្ឋានមានពី ០ដល់១០០

រូបភាពទី១៧: សំណួរស្តីពីការបន្ស៊ីផ្នែកគោលនយោបាយនៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ គិតជាមធ្យម




ចំណាំៈ ០=មិនល្អ ២៥=មិនសូវល្អ ៥០=មធ្យម ៧៥=ល្អ ១០០= ល្អណាស់

តារាងទី៥: ការចាត់ថ្នាក់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋលើសេវាពាក់ព័ន្ធនឹងទឹកឆ្នាំ២០១៦

| បរិយាយ | ចំណាត់ថ្នាក់ប្រជាពលរដ្ឋ | ចំណាត់ថ្នាក់ក្រុមប្រឹក្សា |
|---|---|---|
| ប្រព័ន្ធលូ | #3 | #12 |
| ការជីកអណ្តូង | #5 | #16 |
| ទឹកស្អាត | #7 | #19 |

## 3.2 តើប្រជាពលរដ្ឋនិយាយអ្វីខ្លះ?

ប្រជាពលរដ្ឋត្រូវបានសាកសួរថា "តើតម្រូវការអាទិភាពរបស់រដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌត្រូវនឹងតម្រូវការអាទិភាពរបស់អ្នកដែរឬទេ?" និង "តើរដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌប្រើប្រាស់ធនធានបានត្រឹមត្រូវឬទេ?"។ ចាប់តាំងពីឆ្នាំ២០១១មក ប្រជាពលរដ្ឋបានគិតថាស្ថានភាពនៃការបន្ស៊ីផ្នែកគោលនយោបាយមានការធ្លាក់ចុះ **រូបភាពទី១៧**។

## 3.3 ទំនាក់ទំនងស្ថិតិ

ដើម្បីប្រៀបធៀបតម្រូវការអាទិភាពរបស់ប្រជាពលរដ្ឋ និងក្រុមប្រឹក្សា សំណួរជាច្រើនត្រូវបានសួរទៅកាន់ក្រុមនីមួយៗឲ្យរកនឹកនូវសេវាចំនួន៣ដែលមានសារៈសំខាន់សម្រាប់សហគមន៍របស់គេ។ សេវា

សម្រាប់រដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបានដាក់ចំណាត់ថ្នាក់ ដោយផ្អែកលើចំនួនដងនៃសេវាដែលបានឆ្លើយ។ ឧទាហរណ៍ កាលពីឆ្នាំ២០១១ ប្រជាពលរដ្ឋបានដាក់ចំណាត់ថ្នាក់វិស័យកសិកម្មជាវិស័យសំខាន់ទី៦ ហើយក្រុមប្រឹក្សាឃុំ សង្កាត់ បានដាក់ចំណាត់ថ្នាក់ថាវិស័យកសិកម្មជាវិស័យសំខាន់ទី២។ បន្ទាប់មកចំណាត់ថ្នាក់ដែលដាក់ដោយក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានយកទៅផ្ទួរផ្ទងជាមួយនឹងចំណាត់ថ្នាក់ដាក់ដោយប្រជាពលរដ្ឋ។ ចំពោះរដ្ឋបាលឃុំ សង្កាត់ ភាពខុសគ្នាខ្លាំងបំផុត គឺសកម្មភាពជាអាទិភាពពាក់ព័ន្ធនឹងទឹកស្អាត **តារាងទី៥**។

អ-ការេ (R-squared) នៃទំនាក់ទំនងស្ថិតិនេះ បង្ហាញអំពី "ភាពខិតទៅជិតបំផុត" រវាងតម្រូវការឬសកម្មភាពអាទិភាពរបស់ប្រជាពលរដ្ឋ និងក្រុមប្រឹក្សា។ ពិន្ទុ អ-ការេ មានកម្រិតពី០ដល់១ ដែលតម្លៃតិចជាង០.៣ ត្រូវបានគេបកស្រាយថាមានភាពខិតទៅជិតគ្នាខ្សោយ។ រូបភាពខាងក្រោមបង្ហាញថា ទំនាក់ទំនងស្ថិតិរវាងតម្រូវការអាទិភាពរបស់ប្រជាពលរដ្ឋនឹងក្រុមប្រឹក្សាមានការថយចុះពីឆ្នាំ២០១១-១៦ និងពីឆ្នាំ២០១៣-១៦។

**រូបភាពទី១៨: ទំនាក់ទំនងស្ថិតិនៃតម្រូវការឬសកម្មភាពអាទិភាពរបស់ប្រពលរដ្ឋ និងក្រុមប្រឹក្សា**




ទិន្នន័យលម្អិតនៃការបន្ស៊ីផ្អែកគោលនយោបាយ តាមសូចនាករនីមួយៗមានដូចខាងក្រោម៖

**តារាងទី៦: សន្ទស្សន៍នៃការបន្ស៊ីផ្អែកគោលនយោបាយ (ទិន្នន័យលម្អិត)**

| បរិយាយ | តម្លៃមធ្យម | | | បម្រែបម្រួលជា% | | គួរឲ្យកត់សម្គាល់ | |
|---|---|---|---|---|---|---|---|
| | 2011 | 2013 | 2016 | 2011-16 | 2013 -16 | 2011-16 | 2013 -16 |
| **ការបន្ស៊ីគោលនយោបាយរបស់ឃុំ សង្កាត់** | 53.17 | 49.75 | 43.12 | -18.90% | -13.34% | ✓ | x |
| ការវាយតម្លៃ៖ តម្រូវការអាទិភាពសម្រាប់សហគមន៍ដែលកំណត់ | 65.86 | 59.53 | 54.07 | -17.90% | -9.18% | ✓ | ✓ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ដោយឃុំ សង្កាត់ និងប្រជាពលរដ្ឋដូចគ្នា (PER 3A) | | | | | | | |
| ការវាយតម្លៃ៖ ឃុំសង្កាត់បានប្រើប្រាស់ធនធានបានត្រឹមត្រូវដើម្បីជួយប្រជាពលរដ្ឋ (PER 3C) | 64.67 | 56.94 | 52.16 | -19.34% | -8.39% | ✓ | ✓ |
| ទំនាក់ទំនងស្ថិតិនៃតម្រូវការអាទិភាពរបស់ប្រជាពលរដ្ឋ និងឃុំសង្កាត់ | 28.97 | 32.79 | 23.12 | -20.19% | -29.49% | x | x |
| **សន្ទស្សន៍ការបន្សុីគោលនយោបាយរបស់ក្រុង ស្រុក ខណ្ឌ** | **62.40** | **52.37** | **40.17** | **-35.63%** | **-23.30%** | ✓ | ✓ |
| ការវាយតម្លៃ៖ តម្រូវការអាទិភាពសម្រាប់សហគមន៍ដែលកំណត់ដោយក្រុង ស្រុក ខណ្ឌ និងប្រជាពលរដ្ឋដូចគ្នា (PER 3B) | 66.11 | 57.02 | 53.29 | -19.40% | -6.55% | ✓ | ✓ |
| ការវាយតម្លៃ៖ ក្រុមប្រឹក្សាក្រុងស្រុកខណ្ឌបានប្រើប្រាស់ធនធានបានត្រឹមត្រូវដើម្បីជួយប្រជាពលរដ្ឋ (PER 3D) | 65.98 | 55.78 | 51.98 | -21.22% | -6.80% | ✓ | ✓ |
| ទំនាក់ទំនងស្ថិតិនៃតម្រូវការអាទិភាពរបស់ប្រជាពលរដ្ឋ និងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ | 55.11 | 44.32 | 15.24 | -72.35% | -65.61% | ✓ | ✓ |
| **សន្ទស្សន៍នៃការបន្សុីផ្នែកគោលនយោបាយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ** | **57.78** | **51.06** | **41.64** | **-27.93%** | **-18.45%** | ✓ | x |

ចំណាំ៖ "គួរឲ្យកត់សម្គាល់ "វាស់វែងអំពីថាតើមានការកើនឡើង ឬការថយចុះគួរឲ្យកត់សម្គាល់ក្នុងអត្ថន័យស្ថិតិរវាងឆ្នាំទាំង២ ក្នុងកម្រិតនៃការជឿទុកចិត្ត ៩៥% ។ កូដសម្រាប់សំណួរ (ដូចជា PER4B) ត្រូវបានផ្តល់ដើម្បីផ្ទៀងផ្ទាត់។ សូមកត់ចំណាំថា ការវាយតម្លៃការពេញចិត្តគិតលើមាត្រដ្ឋានពី០ដល់១០០ (Likert Scale) ដោយ 0=មិនល្អ ២៥=មិនសូវល្អ ៥0=មធ្យម ៧៥=ល្អ ១០០=ល្អណាស់

# 4. ការឆ្លើយតប

នៅក្នុងរបាយការណ៍នេះ ពាក្យថា "ការឆ្លើយតប" ត្រូវបានប្រើប្រាស់ដើម្បីរៀបរាប់អំពីកម្រិតដែលថ្នាក់ក្រោមជាតិឆ្លើយតបទៅនឹងបញ្ហាដែលកើតឡើងហើយមានផលប៉ះពាល់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ចំពោះផ្នែកនេះ ការអង្កេតបានពិនិត្យមើលទៅលើ៖ (១). តើប្រជាពលរដ្ឋបានដឹងអំពីយន្តការដាក់ពាក្យបណ្ដឹងដែរ ឬទេ? (២). តើប្រជាពលរដ្ឋចង់ដាក់ពាក្យបណ្ដឹងនិងបានដាក់ពាក្យបណ្ដឹងដែរឬទេ? (៣). តើប្រជាពលរដ្ឋជឿថាពាក្យបណ្ដឹងរបស់គាត់ត្រូវបានដោះស្រាយយ៉ាងពេញចិត្តដែរឬទេ? និង (៥). ការវាយតម្លៃរបស់ប្រជាពលរដ្ឋទៅលើការឆ្លើយតបរបស់ថ្នាក់ក្រោមជាតិ។

## 4.1 និន្នាការនៃការឆ្លើយតបរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**លទ្ធផលនៃការអង្កេតបង្ហាញថា សន្ទស្សន៍ការឆ្លើយតបរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានកើនឡើងពីឆ្នាំ២០១៣-១៦ ប៉ុន្តែតួលេខនេះនៅតែទាបជាងកម្រិតនៃការអង្កេតដើមគ្រាឆ្នាំ២០១១។** បម្រែបម្រួលពីឆ្នាំ២០១១-១៦ និងពីឆ្នាំ២០១៣-១៦ មិនមានអ្វីគួរឲ្យកត់សម្គាល់ក្នុងអត្ថន័យស្ថិតិទេ។

## 4.2 តើប្រជាពលរដ្ឋបានដឹងអំពីយន្តការដោះស្រាយបណ្ដឹងដែរ ឬទេ?

នៅឆ្នាំ២០១៦ មានប្រមាណជា៨៤%នៃប្រជាពលរដ្ឋអាចប្រាប់បានយ៉ាងតិចមួយអំពីយន្តការនៃការដោះស្រាយបណ្ដឹងនៅរដ្ឋបាលឃុំសង្កាត់ ហើយប្រមាណជា១២%អាចប្រាប់បានពីយន្តការដោះស្រាយបណ្ដឹងនៅរដ្ឋបាលក្រុងស្រុកខណ្ឌបានយ៉ាងតិចមួយ។

**រូបភាពទី១៩: និន្នាការសន្ទស្សន៍នៃការឆ្លើយតបរបស់ថ្នាក់ក្រោមជាតិ**




ចំណាំ៖ សន្ទស្សន៍មានមាត្រដ្ឋានពី០ដល់១០០

**រូបភាពទី២០: ការពេញចិត្តរបស់ប្រជាពលរដ្ឋនឹងការដោះស្រាយបណ្ដឹង**




ចំណាំ៖ ០=មិនពេញចិត្តទាល់តែសោះ ២៥=មិនពេញចិត្ត ៥០=មធ្យម ៧៥=ពេញចិត្ត ១០០=ពេញចិត្តខ្លាំង

**រូបភាពទី២១: ការពេញចិត្តរបស់ប្រជាពលរដ្ឋនឹងការដោះស្រាយបណ្ដឹង**




ចំណាំ៖ ០=មិនពេញចិត្តទាល់តែសោះ ២៥=មិនពេញចិត្ត ៥០=មធ្យម ៧៥=ពេញចិត្ត ១០០=ពេញចិត្តខ្លាំង

## 4.3 តើប្រជាពលរដ្ឋមានការពេញចិត្តជាមួយនឹងការដោះស្រាយបណ្តឹងដែរ ឬទេ?

ពីឆ្នាំ២០១១-១៣ ការពេញចិត្តនឹងការដោះស្រាយបណ្តឹងមានការធ្លាក់ចុះគួរឲ្យកត់សម្គាល់។ ប៉ុន្តែការពេញចិត្តនេះ មានការកើនឡើងគួរឲ្យកត់សម្គាល់ក្នុងអត្ថន័យស្ថិតិពីឆ្នាំ២០១១-១៦ **រូបភាពទី២០**។

## 4.4 ការវាយតម្លៃជារួមអំពីការឆ្លើយតប

ជាទូទៅ ប្រជាពលរដ្ឋជឿជាក់ថា រដ្ឋបាលថ្នាក់ក្រោមជាតិមានការឆ្លើយតបកាន់តែប្រសើរជាងមុខ ហើយវាមានការកើនឡើងគួរឲ្យកត់សម្គាល់ក្នុងអត្ថន័យស្ថិតិនៅឆ្នាំ២០១៦ **រូបភាពទី២១**។

## 4.5 តើប្រជាពលរដ្ឋដាក់ពាក្យបណ្តឹងដែរ ឬទេ ពេលដែលគាត់ចង់ប្តឹង?

ទោះបីជាប្រជាពលរដ្ឋបានដឹងអំពីរបៀបដែលត្រូវដាក់ពាក្យបណ្តឹង ហើយធ្លាប់ចង់ដាក់ពាក្យបណ្តឹងក៏ដោយ ជានិច្ចជាកាលគាត់មិនដែលបានដាក់ពាក្យបណ្តឹងទេ។

- នៅឆ្នាំ២០១១ ៣៨.៦%នៃប្រជាពលរដ្ឋចង់ប្តឹង ប៉ុន្តែមិនបានប្តឹង
- នៅឆ្នាំ២០១៣ ៧១.៥%នៃប្រជាពលរដ្ឋប៉ងចង់ប្តឹង ប៉ុន្តែមិនបានប្តឹង
- នៅឆ្នាំ២០១៦ ៧០.១%នៃប្រជាពលរដ្ឋប៉ងចង់ប្តឹង ប៉ុន្តែមិនបានប្តឹង។

តួលេខនេះអាចឆ្លុះបញ្ចាំងពីភាពមិនងាយស្រួល (លទ្ធភាពទាប) នៃការយន្តការដោះស្រាយបណ្តឹង ឬប្រជាពលរដ្ឋយល់ថាបណ្តឹងរបស់គាត់មិនអាចដោះស្រាយបញ្ហាបាន។

ទិន្នន័យនៃការអង្កេតជាមួយប្រជាពលរដ្ឋបានបង្ហាញថា៖

- នៅឆ្នាំ២០១៦ ១៤.៤%នៃប្រជាពលរដ្ឋចង់ប្តឹង ប៉ុន្តែក្នុងចំណោមអ្នកដែលចង់ប្តឹងទាំងអស់មានតែ៧០.១%ប៉ុណ្ណោះបានដាក់ពាក្យបណ្តឹង។

ទិន្នន័យលម្អិតស្តីពីការឆ្លើយតបតាមសូចនាករនីមួយៗមានក្នុង**តារាងទី៧**៖

**រូបភាពទី២២: % នៃប្រជាពលរដ្ឋចង់ ឬមិនចង់ប្តឹង និងបាន ឬមិនបានប្តឹង**



## តារាងទី៧: ទិន្នន័យលម្អិតនៃសន្ទស្សន៍ការឆ្លើយតប

| | តម្លៃមធ្យម | | | បម្រែបម្រួលជា% | | គួរឲ្យកត់សម្គាល់ | |
|---|---|---|---|---|---|---|---|
| | 2011 | 2013 | 2016 | 2011-16 | 2013 -16 | 2011-16 | 2013 -16 |
| **1. សន្ទស្សន៍ការឆ្លើយតបរបស់ក្រុមប្រឹក្សាឃុំសង្កាត់** | **61.15** | **61.08** | **64.91** | **6.15%** | **6.27%** | ✓ | x |
| 1.1. % នៃប្រជាពលរដ្ឋដឹងពីយន្តការដោះស្រាយបណ្ដឹងរបស់រដ្ឋបាលឃុំ សង្កាត់យ៉ាងតិចមួយ | 84.45 | 90.41 | 8<br>3.93 | -0.62% | -7.17% | x | ✓ |
| 1.2. ការវាយតម្លៃ៖ ការពេញចិត្តនឹងការដោះស្រាយបណ្ដឹងរបស់រដ្ឋបាលឃុំ សង្កាត់ | 38.51 | 35.37 | 47.83 | 24.20% | 35.23% | ✓ | x |
| 1.3. ការវាយតម្លៃ៖ ការឆ្លើយតបជារួមរបស់រដ្ឋបាលឃុំ សង្កាត់ | 60.50 | 57.48 | 62.98 | 4.10% | 9.57% | ✓ | ✓ |
| **2. សន្ទស្សន៍ការឆ្លើយតបរបស់ក្រុង ស្រុក ខណ្ឌ** | **37.13** | **31.82** | **40.84** | **9.98%** | **28.32%** | ✓ | x |
| 2.1. % នៃប្រជាពលរដ្ឋដឹងពីយន្តការដោះស្រាយបណ្ដឹងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌយ៉ាងតិចមួយ | 6.40 | 9.22 | 12.20 | 90.70% | 32.36% | ✓ | x |
| 2.2. ការវាយតម្លៃ៖ ការពេញចិត្តនឹងការដោះស្រាយបណ្ដឹងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ | 45.83 | 32.35 | 50.00 | 9.09% | 54.55% | ✓ | x |
| 2.3. ការវាយតម្លៃ៖ ការឆ្លើយតបជារួមរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ | 59.16 | 53.89 | 60.30 | 1.94% | 11.89% | ✓ | ✓ |
| **3. សន្ទស្សន៍ការឆ្លើយតបរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** | **53.22** | **40.80** | **45.21** | **-15.05%** | **10.81%** | x | x |
| 3.1. សន្ទស្សន៍ការឆ្លើយតបរបស់ឃុំ សង្កាត់ (ជួរទី១) | 61.15 | 61.08 | 64.91 | 6.15% | 6.27% | ✓ | x |
| 3.2. សន្ទស្សន៍ការឆ្លើយតបរបស់ក្រុង ស្រុក ខណ្ឌ (ជួរទី២) | 37.13 | 31.82 | 40.84 | 9.98% | 28.32% | ✓ | x |
| 3.3. % នៃប្រជាពលរដ្ឋចង់ប្ដឹង ហើយបានប្ដឹង | 61.39 | 29.50 | 29.90 | -51.30% | 1.33% | ✓ | x |

ចំណាំ៖ "គួរឲ្យកត់សម្គាល់" វាស់វែងអំពីថាតើមានការកើនឡើង ឬការថយចុះគួរឲ្យកត់សម្គាល់ក្នុងអត្ថន័យស្ថិតិដែរឬទេរវាងឆ្នាំទាំង២ នៅក្នុងកម្រិតនៃការជឿទុកចិត្ត៩៥%។ កូដសម្រាប់សំណួរ (ដូចជា PER4B) ត្រូវបានផ្ដល់ដើម្បីផ្ទៀងផ្ទាត់។ ចំណាំ៖ ការវាយតម្លៃការពេញចិត្តគិតលើមាត្រដ្ឋានពី០ដល់១០០ (Likert Scale) ដោយ 0=មិនល្អ ២៥=មិនសូវល្អ ៥០= មធ្យម (មិនល្អ មិនអាក្រក់) ៧៥=ល្អ ១០០= ល្អណាស់

# 5. ការការពារ និងគាំទ្រក្រុមជនងាយរងគ្រោះ

## 5.1 និន្នាការនៃការការពារ និងគាំទ្រក្រុមជនងាយរងគ្រោះ

ផ.អ.៣ មានបំណងធ្វើឲ្យប្រជាពលរដ្ឋមានការរស់នៅកាន់តែប្រសើរឡើង ជាពិសេស "ក្រុមជនងាយរងគ្រោះ" ឬក្រុមដែលមានប្រវត្តិទន់ខ្សោយ។ ក្រុមទាំងនេះរួមមាន ក្រុមជនជាតិភាគតិច ក្រុមយុវជន និងក្រុមជនក្រីក្រ។ ប្រជាពលរដ្ឋត្រូវបានសួរថាតើក្រុមខាងលើត្រូវបានគាំពារនិងគាំទ្រដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំសង្កាត់គ្រប់គ្រាន់ដែរ ឬទេ?[7]

**លទ្ធផលនៃការអង្កេតបង្ហាញថាសន្ទស្សន៍ការគាំទ្រក្រុមជនងាយរងគ្រោះមានការកើនឡើងពីឆ្នាំ២០១៣-១៦ និងពីឆ្នាំ២០១១-១៦។** ការផ្លាស់ប្តូរនេះមានការកើនឡើងគួរឲ្យកត់សម្គាល់ក្នុងអត្ថន័យស្ថិតិ។

រូបភាពទី២៣: និន្នាការនៃសន្ទស្សន៍ការការពារនិងគាំទ្រក្រុមជនងាយរងគ្រោះ




ចំណាំ៖ សន្ទស្សន៍មានមាត្រដ្ឋានពី ០ដល់១០០

## 5.2 ការប្រៀបធៀបតាមក្រុម

ដូចករណីឆ្នាំមុនដែរ (**រូបភាពទី២៤**) ការការពារស្ត្រីនិងកុមារ មានភាពប្រសើរជាងការការពារក្រុមផ្សេងទៀត ហើយការការពារក្រុមជនជាតិភាគតិចនៅទាបជាងគេបង្អស់។ ទិន្នន័យលម្អិតក្នុង**តារាងទី៨** បង្ហាញថា ការជួយគាំទ្ររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ទៅដល់ក្រុមទាំងនេះគឺស្រដៀងគ្នា។

រូបភាពទី២៤: ការប្រៀបធៀបតាមក្រុម (ការវាយតម្លៃជាមធ្យមរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់)




ចំណាំ៖ ០=មិនល្អ ២៥=មិនសូវល្អ ៥០= មធ្យម (មិនល្អ មិនអាក្រក់) ៧៥=ល្អ ១០០=ល្អណាស់

[7] នៅក្នុងឆ្នាំ២០១១ សន្ទស្សន៍ទាំងអស់ ត្រូវបានដាក់ជាក្រុម និងប្រៀបធៀបតាមយេនឌ័រ និងភាពក្រីក្រ។ ការវិភាគនេះបានចំណាយពេលច្រើន ហើយមិនបានធ្វើទេនៅឆ្នាំ២០១៣ និងឆ្នាំ២០១៦

## តារាងទី៨: ទិន្នន័យលម្អិតនៃសន្ទស្សន៍ការគាំទ្រក្រុមជនងាយរងគ្រោះ

| បរិយាយ | តម្លៃមធ្យម 2011 | 2013 | 2016 | បម្រែបម្រួលជា % 2011-16 | 2013 -16 | គួរឲ្យកត់សម្គាល់ 2011-16 | 2013 -16 |
|---|---|---|---|---|---|---|---|
| **1. ការវាយតម្លៃរបស់ប្រជាពលរដ្ឋចំពោះការការពារនិងគាំទ្រក្រុមជនងាយរងគ្រោះដោយរដ្ឋបាលឃុំ សង្កាត់** | **49.00** | **44.55** | **50.36** | **2.77%** | **13.03%** | ✓ | ✓ |
| 1.1. អ្នកក្រ (PER4A) | 49.07 | 44.53 | 50.02 | 1.94% | 12.32% | ✓ | ✓ |
| 1.2. ក្រុមយុវជន (PER4B) | 45.47 | 42.16 | 50.02 | 10.00% | 18.64% | ✓ | ✓ |
| 1.3. ក្រុមស្ត្រី និងកុមារ (PER4C) | 56.53 | 58.54 | 54.15 | -4.21% | -7.50% | X | ✓ |
| 1.4. ក្រុមជនជាតិដើមភាគតិច (PER4D) | 45.37 | 34.42 | 45.28 | -0.19% | 31.58% | X | ✓ |
| 1.5. ក្រុមជនពិការ (PER4E) | 48.56 | 43.12 | 52.32 | 7.74% | 21.33% | ✓ | ✓ |
| **2. ការវាយតម្លៃរបស់ប្រជាពលរដ្ឋចំពោះការការពារនិងគាំទ្រក្រុមជនងាយរងគ្រោះដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌ** | **48.24** | **44.45** | **51.76** | **7.31%** | **16.45%** | ✓ | ✓ |
| 2.1. ជនក្រីក្រ (PER5A) | 48.76 | 44.13 | 51.87 | 6.36% | 17.54% | ✓ | ✓ |
| 2.2. ក្រុមយុវជន (PER5B) | 45.49 | 42.64 | 51.23 | 12.62% | 20.14% | ✓ | ✓ |
| 2.3. ក្រុមស្ត្រី និងកុមារ (PER5C) | 54.34 | 56.61 | 54.56 | 0.41% | -3.62% | ✓ | X |
| 2.4. ក្រុមជនជាតិដើមភាគតិច (PER5D) | 43.91 | 35.80 | 47.73 | 8.70% | 33.31% | ✓ | ✓ |
| 2.5. ក្រុមជនពិការ (PER5E) | 48.68 | 43.08 | 53.44 | 9.77% | 24.04% | ✓ | ✓ |
| **3. សន្ទស្សន៍រួម (មធ្យមទី១ និង២)** | **48.62** | **44.50** | **51.06** | **5.03%** | **14.74%** | ✓ | ✓ |

ចំណាំ៖ "គួរឲ្យកត់សម្គាល់" វាស់វែងអំពីថាតើមានការកើនឡើង ឬការថយចុះគួរឲ្យកត់សម្គាល់ក្នុងអត្ថន័យស្ថិតិដែរ ឬទេរវាងឆ្នាំទាំង២ នៅក្នុងកម្រិតនៃការជឿទុកចិត្ត៩៥%។ កូដសម្រាប់សំណួរ (ដូចជា PER4B) ត្រូវបានផ្តល់ដើម្បីផ្ទៀងផ្ទាត់។ ចំណាំ៖ ការវាយតម្លៃការពេញចិត្តគិតលើមាត្រដ្ឋានពី០ដល់១០០ (Likert Scale) ដោយ 0=មិនល្អ ២៥=មិនសូវល្អ ៥0= មធ្យម (មិនល្អ មិនអាក្រក់) ៧៥=ល្អ ១០០=ល្អណាស់

# 6. ការចូលរួមរបស់ប្រជាពលរដ្ឋ

ការចូលរួមរបស់ប្រជាពលរដ្ឋជាដំណើរការសហគមន៍មូលដ្ឋានមួយ ដែលប្រជាពលរដ្ឋរៀបចំគោលដៅរបស់គេ និងធ្វើសកម្មភាពជាលក្ខណៈបុគ្គល ឬជាក្រុមតាមរយៈអង្គការសហគមន៍មិនមែនរាជរដ្ឋាភិបាល ដើម្បីធ្វើឲ្យមានឥទ្ធិពលទៅលើដំណើរការនៃការសម្រេចចិត្តជាសាធារណៈ[៨]។ ការចូលរួមនេះ មិនមែនគ្រាន់តែជាវត្តមានក្នុងកិច្ចប្រជុំនោះទេ។ ផ.អ.៣ទី១ (ទំព័រទី១៤) បានឲ្យនិយមន័យនៃការចូលរួមរបស់ប្រជាពលរដ្ឋ គឺមិនត្រឹមជាការស្តាប់ប្រជាពលរដ្ឋទេ វាគឺជាដំណើរការទៅមក តាមរយៈការស្តាប់ប្រជាពលរដ្ឋ ព្រមទាំងការពន្យល់និងផ្តល់ហេតុផលរបស់ក្រុមប្រឹក្សាអំពីការសម្រេចចិត្តរបស់គេទៅប្រជាពលរដ្ឋនិងសហគមន៍។ ដើម្បីវាយតម្លៃពីការចូលរួមរបស់ប្រជាពលរដ្ឋ ការអង្កេតបានពិនិត្យលើ៣ចំណុចដូចជា៖ (១). ភាពញឹកញាប់នៃទំនាក់ទំនងក្រៅផ្លូវការរវាងក្រុមប្រឹក្សា និងប្រជាពលរដ្ឋ (២). ការចូលរួម និងការវាយតម្លៃពីប្រយោជន៍ និងប្រសិទ្ធិភាពនៃការធ្វើផែនការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងការចូលរួមប្រជុំដ៏ទៃទៀត និង (៣). ការចូលរួមរបស់ប្រជាពលរដ្ឋ និងការវាយតម្លៃពីប្រសិទ្ធិភាពនៃអង្គការសង្គមស៊ីវិលក្នុងមូលដ្ឋាន។

## 6.1 និន្នាការនៃសន្ទស្សន៍ការចូលរួមរបស់ប្រជាពលរដ្ឋ

